រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៣៦៧៨ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពី
ការចារចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធអេឡិចត្រូនិក

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្នុំកូនអន្តរប្រទេស

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩២៥/០៣០ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ ស្តីពីសមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១.- គោលបំណង

ប្រកាសនេះ កំណត់អំពីទម្រង់ បែបបទ និងនីតិវិធីនៃការងារចុះបញ្ជីអត្រានុកូលដ្ឋាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការងារអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា។

ប្រការ២.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់ការងារចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធអេឡិចត្រូនិកដល់ជនគ្រប់រូបដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

ប្រការ៣.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **កំណើតរស់** សំដៅដល់ការធាក់ចេញ ឬការទាញចេញពេញលេញនូវផលិតផលគភ៌ពីម្តាយ ដោយមិនគិតរយៈពេលនៃការមានគភ៌ ហើយបន្ទាប់ពីការបំបែកចេញពីម្តាយនោះ ទារកមានដង្ហើម ឬបង្ហាញកស្តុតាងដទៃទៀតនៃជីវិត ដូចជាបេះដូងលោត មានជីពចរ ទងសុក ឬសាច់ដុំមានចលនាជាក់លាក់មិនថាទងសុកត្រូវបានកាត់ផ្តាច់ ឬមានជាប់សុកមកជាមួយក្តី។

- **ក្នុងរយៈពេលអនុគ្រោះមួយឆ្នាំ** សំដៅដល់រយៈពេលនៃការចុះបញ្ជីកំណើតរស់ដែលទុកឱ្យហួសរយៈពេល ៣០(សាមសិប)ថ្ងៃ និងការចុះបញ្ជីមរណភាពដែលទុកឱ្យហួសរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ មិនឱ្យហួសរយៈពេលមួយឆ្នាំ ដោយគិតចាប់ពីព្រឹត្តិការណ៍ដែលបានកើតឡើង។
- **ក្រោយផុតរយៈពេលអនុគ្រោះមួយឆ្នាំ** សំដៅដល់រយៈពេលនៃការចុះបញ្ជីកំណើតរស់ និងការចុះបញ្ជីមរណភាពដែលទុកឱ្យហួសរយៈពេលមួយឆ្នាំនៃព្រឹត្តិការណ៍ដែលបានកើតឡើង។
- **បច្ឆាញាតិផ្ទាល់** សំដៅដល់ជន ឬពួកជន ដែលកើតពីជនមួយពួកទៀត។ ឧទាហរណ៍៖ កូន ជាបច្ឆាញាតិរបស់ឪពុកម្តាយ។ ចៅ ជាបច្ឆាញាតិរបស់ជីដូនជីតា។
- **មរណភាព** សំដៅដល់ការបាត់បង់ជាអចិន្ត្រៃយ៍នូវរាល់កស្តុតាង នៃជីវិតនៅក្នុងពេលណាមួយក្រោយកំណើតរស់។
- **មូលដ្ឋានសុខាភិបាល** សំដៅដល់មូលដ្ឋានសុខាភិបាលសាធារណៈ និងមូលដ្ឋានសុខាភិបាលឯកជន។
- **មូលដ្ឋានសុខាភិបាលសាធារណៈ** សំដៅដល់មន្ទីរពេទ្យជាតិ រួមទាំងមន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាល និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព។
- **មូលដ្ឋានសុខាភិបាលឯកជន** សំដៅដល់មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាលមន្ទីរសម្ភព-រោគស្ត្រី និងគ្លីនិកឯកជន។
- **ស្ថានភាពអាពាហ៍ពិពាហ៍** សំដៅដល់ស្ថានភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ ឬមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។
- **សំបុត្រអត្រានុកូលដ្ឋាន** សំដៅដល់ឯកសារក្នុងទម្រង់ជាក្រដាស ឬអេឡិចត្រូនិក ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានដែលមានព័ត៌មានដូចគ្នាទាំងស្រុង ឬមួយផ្នែកនៃព័ត៌មាននៅក្នុងកំណត់ត្រានៃបញ្ជីអត្រានុកូលដ្ឋាន ហើយក្រោយពេលបានចេញដោយមន្ត្រីអត្រានុកូលដ្ឋានរួចហើយនឹងត្រូវមានអានុភាពនិងសុពលភាពពេញលេញដូចកំណត់ត្រានៃបញ្ជីអត្រានុកូលដ្ឋាន។
- **អ្នករាយការណ៍** សំដៅដល់បុគ្គល ឬស្ថាប័នដែលច្បាប់បានកំណត់ឱ្យរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអំពីព្រឹត្តិការណ៍ជីវិតដែលបានកើតឡើង និងផ្តល់រាល់ព័ត៌មាននិងចរិតលក្ខណៈទាំងអស់នៃព្រឹត្តិការណ៍នោះ សម្រាប់ជាមូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចធ្វើការចុះបញ្ជីព្រឹត្តិការណ៍នោះតាមផ្លូវច្បាប់។
- **អាពាហ៍ពិពាហ៍** សំដៅដល់កិច្ចសន្យាពិសេសដែលកើតចេញពីឆន្ទៈព្រមព្រៀងរវាងបុរសម្នាក់ និងនារីម្នាក់ ដែលមានបំណងរួមរស់ជាមួយគ្នា និងសង្គ្រោះគ្នាទៅវិញទៅមក ហើយបុរស និងនារីនោះត្រូវតែមានលក្ខខណ្ឌដូចបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។
- **ឈ្មោះអ្នកកើត** សំដៅដល់នាមត្រកូល និងនាមខ្លួនរបស់អ្នកកើត។
- **មន្ត្រីទទួលពាក្យ** សំដៅដល់មន្ត្រីមានភារកិច្ចពិនិត្យ និងទទួលពាក្យសុំនៅឯការិយាល័យ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស និងនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

- **មន្ត្រីទទួលបន្ទុក** សំដៅដល់មន្ត្រីមានការកិច្ចចាត់ចែងការងារអត្រានុកូលដ្ឋាន នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងនៅនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។
- **បណ្តឹងឧបាស្រ័យ** សំដៅដល់ការប្តឹងមិនសុខចិត្តទៅនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីទទួលការងារអត្រានុកូលដ្ឋាន និងមន្ត្រីអត្រានុកូលដ្ឋាន តាមឋានានុក្រម។

ជំពូកទី២
បទប្បញ្ញត្តិរួម

ប្រការ៤.- ការងារចុះបញ្ជីអត្រានុកូលដ្ឋាន

ការងារចុះបញ្ជីអត្រានុកូលដ្ឋាន រួមមាន ការចុះបញ្ជីកំណើតរស់ ការចុះបញ្ជីមរណភាព ការចុះបញ្ជីអាពាហ៍ពិពាហ៍ ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន ការកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ការផ្តល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញ ក្នុងករណីខូចខាត ឬបាត់បង់ ការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត ការធ្វើបច្ចុប្បន្នភាពបញ្ជីអត្រានុកូលដ្ឋាន ការថែទាំ ការរក្សាទុក ការបញ្ជូនបញ្ជី ព័ត៌មាន និងរបាយការណ៍ស្តីពីការងារអត្រានុកូលដ្ឋាននិងបណ្តឹងមិនសុខចិត្ត។

ប្រការ៥.- សារប្រយោជន៍សំបុត្រអត្រានុកូលដ្ឋាន

សំបុត្រអត្រានុកូលដ្ឋានមានសារសំខាន់ សម្រាប់ផ្សារភ្ជាប់បុគ្គលម្នាក់ទៅនឹងព្រឹត្តិការណ៍ជីវិតមួយដែលអាចយកមកប្រើប្រាស់ដើម្បីបង្កើតនូវសិទ្ធិ និងកាតព្វកិច្ច នៅពេលដែលបុគ្គលនោះនៅមានជីវិត ឬក្រោយពេលមរណភាព។

ជំពូកទី៣
ទម្រង់ និងព័ត៌មានបញ្ជីអត្រានុកូលដ្ឋាន សំបុត្រអត្រានុកូលដ្ឋាន សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន
ផ្នែកទី១
ទម្រង់ និងព័ត៌មានបញ្ជីអត្រានុកូលដ្ឋាន

ប្រការ៦.- ទម្រង់ និងព័ត៌មានបញ្ជីកំណើតរស់

ព័ត៌មាននៅក្នុងបញ្ជីកំណើតរស់ មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់អ្នកកើត
- ភេទរបស់អ្នកកើត
- សញ្ជាតិរបស់អ្នកកើត
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកកើត
- ទីកន្លែងកំណើតរបស់អ្នកកើត
- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់អ្នកកើត

- នាមត្រកូល និងនាមខ្លួនឪពុកម្តាយរបស់អ្នកកើត
- សញ្ជាតិឪពុកម្តាយរបស់អ្នកកើត
- ថ្ងៃ ខែ ឆ្នាំកំណើតឪពុកម្តាយរបស់អ្នកកើត
- ទីកន្លែងកំណើតឪពុកម្តាយរបស់អ្នកកើត។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃបញ្ជីកំណើតរស់ជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី១** នៃប្រកាសនេះ។

ករណីបញ្ជីកំណើតរស់ក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្ទង់ទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៧.- ទម្រង់ និងព័ត៌មានបញ្ជីមរណភាព

ព័ត៌មាននៅក្នុងបញ្ជីមរណភាព មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់មរណជន
- ភេទរបស់មរណជន
- សញ្ជាតិរបស់មរណជន
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់មរណជន
- ថ្ងៃ ខែ ឆ្នាំទទួលមរណភាព
- ទីកន្លែងទទួលមរណភាព
- នាមត្រកូល និងនាមខ្លួនរបស់ឪពុកម្តាយនៃមរណជន
- សញ្ជាតិរបស់ឪពុកម្តាយនៃមរណជន
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុកម្តាយនៃមរណជន។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃបញ្ជីមរណភាពជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី២** នៃប្រកាសនេះ។

ករណីបញ្ជីមរណភាពក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្ទង់ទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៨.- ទម្រង់ និងព័ត៌មានបញ្ជីអាពាហ៍ពិពាហ៍

ព័ត៌មាននៅក្នុងបញ្ជីអាពាហ៍ពិពាហ៍ មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់ប្តីប្រពន្ធ
- សញ្ជាតិរបស់ប្តីប្រពន្ធ
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់ប្តីប្រពន្ធ
- ទីកន្លែងកំណើតរបស់ប្តីប្រពន្ធ
- លំនៅឋានបច្ចុប្បន្នរបស់ប្តីប្រពន្ធ
- នាមត្រកូល និងនាមខ្លួនឪពុកម្តាយរបស់ប្តីប្រពន្ធ
- សញ្ជាតិឪពុកម្តាយរបស់ប្តីប្រពន្ធ

- ថ្ងៃ ខែ ឆ្នាំកំណើតឪពុកម្តាយរបស់ប្តីប្រពន្ធ។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃបញ្ជីអាពាហ៍ពិពាហ៍ជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី៣** នៃប្រកាសនេះ។

ករណីបញ្ជីអាពាហ៍ពិពាហ៍ក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្ចង់ទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ផ្នែកទី២
ទម្រង់ និងព័ត៌មានសំបុត្រអត្រានុកូលដ្ឋាន

ប្រការ៩.- ទម្រង់ និងព័ត៌មានសំបុត្រកំណើត

ព័ត៌មាននៅក្នុងសំបុត្រកំណើត មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់អ្នកកើត
- ភេទរបស់អ្នកកើត
- សញ្ជាតិរបស់អ្នកកើត
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកកើត
- ទីកន្លែងកំណើតរបស់អ្នកកើត
- ថ្ងៃ ខែ ឆ្នាំចុះបញ្ជីកំណើត
- ទីកន្លែងចុះបញ្ជី
- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់អ្នកកើត
- នាមត្រកូល និងនាមខ្លួនឪពុកម្តាយរបស់អ្នកកើត
- សញ្ជាតិឪពុកម្តាយរបស់អ្នកកើត
- ថ្ងៃ ខែ ឆ្នាំកំណើតឪពុកម្តាយរបស់អ្នកកើត
- ទីកន្លែងកំណើតឪពុកម្តាយរបស់អ្នកកើត។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃសំបុត្រកំណើតជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី៤** នៃប្រកាសនេះ។

ប្រការ១០.- ទម្រង់ និងព័ត៌មានសំបុត្រមរណភាព

ព័ត៌មាននៅក្នុងសំបុត្រមរណភាព មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់មរណជន
- ភេទរបស់មរណជន
- សញ្ជាតិរបស់មរណជន
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់មរណជន
- ទីកន្លែងកំណើតរបស់មរណជន
- ថ្ងៃ ខែ ឆ្នាំទទួលមរណភាព

- ទីកន្លែងទទួលមរណភាព
- ថ្ងៃ ខែ ឆ្នាំចុះបញ្ជីមរណភាព
- ទីកន្លែងចុះបញ្ជីមរណភាព។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃសំបុត្រមរណភាពជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី៥** នៃប្រកាសនេះ។

ប្រការ១១.- ទម្រង់ និងព័ត៌មានសំបុត្រអាពាហ៍ពិពាហ៍

ព័ត៌មាននៅក្នុងសំបុត្រអាពាហ៍ពិពាហ៍ មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់ប្តីប្រពន្ធ
- សញ្ជាតិរបស់ប្តីប្រពន្ធ
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់ប្តីប្រពន្ធ
- ទីកន្លែងកំណើតរបស់ប្តីប្រពន្ធ
- ថ្ងៃ ខែ ឆ្នាំចុះបញ្ជី
- ទីកន្លែងចុះបញ្ជី។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃសំបុត្រអាពាហ៍ពិពាហ៍ជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី៦** នៃប្រកាសនេះ។

ផ្នែកទី៣
ទម្រង់ និងព័ត៌មានសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន

ប្រការ១២.- ទម្រង់ និងព័ត៌មានសេចក្តីចម្លងសំបុត្រកំណើត

ព័ត៌មាននៅក្នុងសេចក្តីចម្លងសំបុត្រកំណើត ត្រូវមានព័ត៌មានដូចសំបុត្រកំណើតច្បាប់ដើម ដូចកំណត់ក្នុងប្រការ៩ នៃប្រកាសនេះ។

ទម្រង់ និងព័ត៌មានសេចក្តីចម្លងសំបុត្រកំណើតជាក្រដាស ជា**ឧបសម្ព័ន្ធទី៧** នៃប្រកាសនេះ។

ប្រការ១៣.- ទម្រង់ និងព័ត៌មានសេចក្តីចម្លងសំបុត្រមរណភាព

ព័ត៌មាននៅក្នុងសេចក្តីចម្លងសំបុត្រមរណភាព ត្រូវមានព័ត៌មានដូចសំបុត្រមរណភាពច្បាប់ដើម ដូចកំណត់ក្នុងប្រការ១០ នៃប្រកាសនេះ។

ទម្រង់ និងព័ត៌មានសេចក្តីចម្លងសំបុត្រមរណភាពជាក្រដាស ជា**ឧបសម្ព័ន្ធទី៨** នៃប្រកាសនេះ។

ប្រការ១៤.- ទម្រង់ និងព័ត៌មានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

ព័ត៌មាននៅក្នុងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវមានព័ត៌មានដូចសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមដូចកំណត់ក្នុងប្រការ១១ នៃប្រកាសនេះ។

ទម្រង់ និងព័ត៌មានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ជាក្រដាស ជា**ឧបសម្ព័ន្ធទី៩** នៃប្រកាសនេះ។

ផ្នែកទី៤
ទម្រង់ និងព័ត៌មានសម្រង់បញ្ជីអត្រានុកូលដ្ឋាន

ប្រការ១៥.- ទម្រង់ និងព័ត៌មានសម្រង់បញ្ជីកំណើតរស់

ព័ត៌មាននៅក្នុងសម្រង់បញ្ជីកំណើតរស់ មានព័ត៌មានដូចបញ្ជីកំណើតរស់ ដូចកំណត់ក្នុងប្រការ៦ នៃប្រកាសនេះ។

ទម្រង់ និងព័ត៌មានសម្រង់បញ្ជីកំណើតរស់ជាក្រដាស ជាឧបសម្ព័ន្ធទី១០ នៃប្រកាសនេះ។

ប្រការ១៦.- ទម្រង់ និងព័ត៌មានសម្រង់បញ្ជីមរណភាព

ព័ត៌មាននៅក្នុងសម្រង់បញ្ជីមរណភាព មានព័ត៌មានដូចបញ្ជីមរណភាព ដូចកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ។

ទម្រង់ និងព័ត៌មានសម្រង់បញ្ជីមរណភាពជាក្រដាស ជាឧបសម្ព័ន្ធទី១១ នៃប្រកាសនេះ។

ប្រការ១៧.- ទម្រង់ និងព័ត៌មានសម្រង់បញ្ជីអាពាហ៍ពិពាហ៍

ព័ត៌មាននៅក្នុងសម្រង់បញ្ជីអាពាហ៍ពិពាហ៍ មានព័ត៌មានដូចបញ្ជីអាពាហ៍ពិពាហ៍ ដូចកំណត់ក្នុងប្រការ៨ នៃប្រកាសនេះ។

ទម្រង់ និងព័ត៌មានសម្រង់បញ្ជីអាពាហ៍ពិពាហ៍ជាក្រដាស ជាឧបសម្ព័ន្ធទី១២ នៃប្រកាសនេះ។

ជំពូកទី៤
ការចុះបញ្ជីកំណើតរស់
ផ្នែកទី១
អ្នករាយការណ៍អំពីកំណើតរស់

ប្រការ១៨.- អ្នករាយការណ៍អំពីកំណើតរស់

អ្នករាយការណ៍អំពីកំណើតរស់ ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោម៖

ក- ម្តាយរបស់ទារក។

ខ- ឪពុករបស់ទារក។

គ- អ្នកអាណាព្យាបាលទូទៅរបស់ឪពុកម្តាយទារក។

ឃ- ញាតិជានីតិជនដែលមើលថែទារក។

ង- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀតដែលកំណត់ដោយច្បាប់។

ផ្នែកទី២
ទម្រង់ បែបបទ និងការដាក់ពាក្យសុំចុះបញ្ជីកំណើតរស់

ប្រការ១៩.- ទម្រង់ និងព័ត៌មានពាក្យសុំចុះបញ្ជីកំណើតរស់

ព័ត៌មាននៅក្នុងពាក្យសុំចុះបញ្ជីកំណើតរស់ មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់ទារក

- ភេទរបស់ទារក
- ថ្ងៃ ខែ ឆ្នាំកំណើត ម៉ោង និងទីកន្លែងទារកកើតរស់
- នាមត្រកូល និងនាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល សញ្ជាតិ និងលំនៅឋានរបស់ឪពុកម្តាយនៃទារក
- នាមត្រកូល និងនាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នករាយការណ៍ ក្នុងករណីដែលអ្នករាយការណ៍មិនមែនជាម្តាយឬឪពុក
- ថ្ងៃ ខែ ឆ្នាំ ដាក់ពាក្យសុំ។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃពាក្យសុំចុះបញ្ជីកំណើតរស់ជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី១៣** នៃប្រកាសនេះ។

ករណីពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្នង់ទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ២០.- ទីកន្លែង និងការដាក់ពាក្យសុំចុះបញ្ជីកំណើតរស់

ការដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ ត្រូវអនុវត្តតាមការកំណត់ដូចខាងក្រោម៖

១. ក្នុងករណីកំណើតរស់ដែលបានកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នករាយការណ៍អាចដាក់ពាក្យសុំនៅរដ្ឋបាលឃុំ សង្កាត់ ដែលកំណើតរស់បានកើតឡើង ឬរដ្ឋបាលឃុំ សង្កាត់ ដែលអ្នករាយការណ៍ស្នាក់នៅ។

២. ក្នុងករណីកំណើតរស់ដែលបានកើតឡើងនៅបរទេស អ្នករាយការណ៍អាចដាក់ពាក្យសុំនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស នៃទីកន្លែងដែលកំណើតរស់បានកើតឡើង។

៣. ក្នុងករណីគ្មានស្ថានតំណាង ឬពុំអាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ ឬពុំមានលទ្ធភាពចុះបញ្ជីកំណើតរស់នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស អ្នករាយការណ៍អាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់នៅរដ្ឋបាលឃុំ សង្កាត់ ដែលអ្នករាយការណ៍ស្នាក់នៅ ក្រោយពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ។

៤. ក្នុងករណីកុមារកំពុងរស់នៅក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ដែលពុំមានសំបុត្រកំណើត ប្រធានមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារក្នុងនាមជាអ្នករាយការណ៍ ត្រូវដាក់ពាក្យនៅរដ្ឋបាលថ្នាក់ឃុំ សង្កាត់ ដែលមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារស្ថិតនៅ។

៥. ក្នុងករណីទារកដែលត្រូវគេបោះបង់ចោល ជនដែលរើសទារកបាននោះ ត្រូវផ្តល់ព័ត៌មានអំពីព្រឹត្តិការណ៍នោះ ទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ នៃឃុំ សង្កាត់ដែលទារកត្រូវបានរើសបានដោយគ្មានការយឺតយ៉ាវ។ ក្នុងករណីនេះ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ត្រូវកត់ត្រាព័ត៌មាននិងចុះបញ្ជីកំណើតរស់របស់ទារកនោះ ដោយកំណត់ឈ្មោះទារក ទោះបីគ្មានអ្នករាយការណ៍ដាក់ពាក្យសុំក៏ដោយ។

៦. ក្នុងករណីទារកដែលកើតពីស្ត្រីជាជនជាប់ឃុំក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា ប្រធានពន្ធនាគារ ឬប្រធានមណ្ឌលយុវនីតិសម្បទា ក្នុងនាមជាអ្នករាយការណ៍ ត្រូវដាក់ពាក្យនៅរដ្ឋបាលថ្នាក់ឃុំ សង្កាត់ នៃពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទាស្ថិតនៅ។

៧. ក្នុងករណីទារកដែលបានកើតតាមរថភ្លើង នាវា អាកាសយាន ឬយានជំនិះសាធារណៈផ្សេងទៀត អ្នករាយការណ៍អាចដាក់ពាក្យសុំទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ដែលរថភ្លើង នាវា អាកាសយានឬយានជំនិះនោះឈប់ចត ឬនៅឃុំ សង្កាត់ ដែលអ្នករាយការណ៍ស្នាក់នៅ។

ការដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ឬតាមទម្រង់អេឡិចត្រូនិក។

ផ្នែកទី៣
ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីកំណើតរស់

ប្រការ២១.- ឯកសារបញ្ជាក់អំពីកំណើតរស់

ឯកសារបញ្ជាក់អំពីកំណើតរស់សម្រាប់ចុះបញ្ជី ត្រូវបានកំណត់ដូចខាងក្រោម៖

១. ក្នុងករណីការចុះបញ្ជីកំណើតរស់ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ អ្នករាយការណ៍ត្រូវផ្តល់ជូននូវឯកសារដូចខាងក្រោម៖

- លិខិតជូនដំណឹងអំពីកំណើតរស់ចេញដោយមូលដ្ឋានសុខាភិបាល ឬ
- លិខិតបញ្ជាក់អំពីកំណើតរស់ចេញដោយមេភូមិនៃទីកន្លែងដែលទារកបានកើត ឬ
- ភស្តុតាងបញ្ជាក់អំពីកំណើតរស់ ឬសំបុត្រកំណើតពីប្រទេសដែលទារកបានកើត។

២. ក្នុងករណីការចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ អ្នករាយការណ៍ត្រូវផ្តល់ជូននូវឯកសារដូចខាងក្រោម៖

ក- ឯកសារបញ្ជាក់អំពីកំណើតរស់

- លិខិតជូនដំណឹងអំពីកំណើតរស់ចេញដោយមូលដ្ឋានសុខាភិបាល ឬបណ្ណសុខភាពកុមារ ឬ
- លិខិតបញ្ជាក់អំពីកំណើតរស់ចេញដោយមេភូមិនៃទីកន្លែងដែលទារកបានកើត ឬ
- ភស្តុតាងបញ្ជាក់អំពីកំណើតរស់ ឬសំបុត្រកំណើតពីប្រទេសដែលទារកបានកើត។

ខ- ការបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។

៣. ក្នុងករណីការចុះបញ្ជីកំណើតរស់ក្រោយផុតរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ អ្នករាយការណ៍ត្រូវផ្តល់ជូននូវឯកសារដូចខាងក្រោម៖

ក- ឯកសារបញ្ជាក់អំពីកំណើតរស់

- លិខិតជូនដំណឹងអំពីកំណើតរស់ចេញដោយមូលដ្ឋានសុខាភិបាល ឬបណ្ណសុខភាពកុមារ ឬ
- លិខិតបញ្ជាក់អំពីកំណើតរស់ចេញដោយមេភូមិនៃទីកន្លែងដែលទារកបានកើត ឬ
- ភស្តុតាងបញ្ជាក់អំពីកំណើតរស់ ឬសំបុត្រកំណើតពីប្រទេសដែលទារកបានកើត។

ខ- ការបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។

គ- ការធានាអះអាងរបស់សាក្សី ១(មួយ)រូប ជានីតិជន ដែលជាប្រជាពលរដ្ឋខ្មែរ ឬជនបរទេស ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ដែលដឹងអំពីកំណើតរស់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយភ្ជាប់ឯកសារអត្តសញ្ញាណមកជាមួយ។

ប្រការ២២.- ឯកសារអត្តសញ្ញាណរបស់ម្តាយ និង/ឬឪពុក

ឯកសារអត្តសញ្ញាណរបស់ម្តាយ និង/ឬឪពុក ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សម្រាប់ប្រជាពលរដ្ឋខ្មែរ

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬ
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬ
- លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល។

ខ- សម្រាប់ជនបរទេស

- សំបុត្រកំណើត ឬ
- លិខិតឆ្លងដែន ឬ
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត ឬ
- ឯកសារអត្តសញ្ញាណផ្សេងទៀតចេញដោយប្រទេសសាមី ឬស្ថានទូត។

ក្នុងករណីឪពុក និង/ឬម្តាយរបស់អ្នកកើតជាជនបរទេស មិនមានឯកសារអត្តសញ្ញាណដូចបានកំណត់ក្នុងចំណុច "ខ" ខាងលើនេះ ត្រូវមានលិខិតអះអាងជាលាយលក្ខណ៍អក្សរជូនមន្ត្រីអត្រានុកូលដ្ឋាន។

ប្រការ២៣.- ឯកសារបញ្ជាក់អំពីបិតុភាព

ឯកសារបញ្ជាក់អំពីបិតុភាព ត្រូវបានកំណត់ដូចខាងក្រោម៖

- សំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ
- លិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ឬ
- ការទទួលស្គាល់ដោយស្ម័គ្រចិត្តនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ជាមួយនឹងការយល់ព្រមពីម្តាយ នៅពេលចុះបញ្ជី ឬ
- សេចក្តីសម្រេចរបស់តុលាការទទួលស្គាល់កូន។

ប្រការ២៤.- ឯកសារបញ្ជាក់អំពីការស្នាក់នៅ

ឯកសារបញ្ជាក់អំពីការស្នាក់នៅ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ ចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬ

ខ- ឯកសារផ្សេងទៀតដែលបញ្ជាក់អំពីការស្នាក់នៅ។

ប្រការ២៥.- ឯកសារបញ្ជាក់អំពីសញ្ជាតិរបស់ឪពុក និង/ឬម្តាយ

ឯកសារបញ្ជាក់សញ្ជាតិរបស់ឪពុក និង/ឬម្តាយ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សម្រាប់ប្រជាពលរដ្ឋខ្មែរ

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬ
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬ
- ឯកសារផ្សេងទៀតដែលបញ្ជាក់អំពីសញ្ជាតិ។

ខ- សម្រាប់ជនបរទេស

- លិខិតឆ្លងដែន ឬ
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត។

ប្រការ២៦.- ឯកសារអត្តសញ្ញាណរបស់អ្នករាយការណ៍មិនមែនជាឪពុក ឬម្តាយ

ប្រសិនបើអ្នករាយការណ៍មិនមែនជាឪពុក ឬម្តាយរបស់អ្នកកើតត្រូវផ្តល់ឯកសារអត្តសញ្ញាណរបស់ខ្លួនត្រូវបានកំណត់ដូចខាងក្រោម៖

ក- សម្រាប់ប្រជាពលរដ្ឋខ្មែរ

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬ
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬ
- លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល។

ខ- សម្រាប់ជនបរទេស

- សំបុត្រកំណើត ឬ
- លិខិតឆ្លងដែន ឬ
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត ឬ
- ឯកសារអត្តសញ្ញាណផ្សេងទៀតចេញដោយប្រទេសសាមី ឬស្ថានតំណាង។

ផ្នែកទី៤
នីតិវិធីនៃការចុះបញ្ជីកំណើតរស់

ប្រការ២៧.- ដំណើរការចុះបញ្ជីកំណើតរស់

ការចុះបញ្ជីកំណើតរស់ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់សម្រាប់ចុះបញ្ជីកំណើតរស់ដែលគ្រប់គ្រាន់ និងត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តការកិច្ចដូចខាងក្រោម៖

- កត់ត្រាព័ត៌មានពាក់ព័ន្ធនឹងកំណើតរស់ ទៅក្នុងពាក្យសុំនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន

- ករណីអ្នករាយការណ៍មានលិខិតជូនដំណឹងអំពីកំណើតរស់ ចេញដោយមូលដ្ឋានសុខាភិបាល ត្រូវវាយបញ្ចូលលេខសម្គាល់ ឬស្កែនលេខកូដឆ្លើយតបរហ័ស (QR) នៃលិខិតជូនដំណឹងអំពីកំណើតរស់ និងបញ្ចូលព័ត៌មាននោះ ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន
- បោះពុម្ពពាក្យសុំចុះបញ្ជីកំណើតរស់ឱ្យអ្នករាយការណ៍ផ្តិតស្នាមម្រាមដៃ
- ស្កែនពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

២. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ជាមួយពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់។ បន្ទាប់ពីបានពិនិត្យឃើញថាត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ត្រូវស្នើសុំទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល។ ចំពោះមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវសម្រេចចុះបញ្ជីកំណើតរស់នៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន បន្ទាប់ពីទទួលបានលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល។

៤. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវបោះពុម្ពបញ្ជីកំណើតរស់ចំនួន ១(មួយ)ច្បាប់ និងសំបុត្រកំណើតចំនួន ១(មួយ)ច្បាប់ ដើម្បីឱ្យអ្នករាយការណ៍ ផ្តិតស្នាមម្រាមដៃលើបញ្ជីកំណើតរស់ មុននឹងដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខា និងបោះត្រា រួចប្រគល់សំបុត្រកំណើតច្បាប់ដើមជូនអ្នករាយការណ៍។

៥. ករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា មិនអាចចុះបញ្ជីកំណើតរស់ក្នុងពេលដាក់ពាក្យសុំបាន មន្ត្រីទទួលពាក្យសុំនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវចេញបង្កាន់ដៃចំនួន ២ច្បាប់ ដោយ ១(មួយ)ច្បាប់ ជូនអ្នករាយការណ៍ និង១(មួយ)ច្បាប់ ទៀតរក្សាទុកនៅទីកន្លែងដាក់ពាក្យសុំ។ ករណីនេះ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យសម្រេចចុះបញ្ជីកំណើតរស់ និងចេញសំបុត្រកំណើតច្បាប់ដើមចំនួន ១(មួយ)ច្បាប់ ជូនអ្នករាយការណ៍មិនឱ្យលើសរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។



៦. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវស្កែនបញ្ជីកំណើតរស់ និងសំបុត្រកំណើតចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកបញ្ជីកំណើតរស់ ពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់នៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។

ព័ត៌មានអប្បបរមាដែលចាំបាច់ សម្រាប់ការចុះបញ្ជីកំណើតរស់ រួមមាន ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតរបស់អ្នកកើត។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវបដិសេធការចុះបញ្ជីកំណើតរស់ទេ ប្រសិនបើអ្នករាយការណ៍មិនអាចផ្តល់ព័ត៌មានផ្សេងទៀតដែលមាននៅក្នុងពាក្យសុំចុះបញ្ជីកំណើតរស់។

ប្រការ២៨.- ការកត់ត្រាខ្នង់សញ្ជាតិនៅពេលចុះបញ្ជីកំណើតរស់

ការកត់ត្រាខ្នង់សញ្ជាតិនៅពេលចុះបញ្ជីកំណើតរស់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សម្រាប់ប្រជាពលរដ្ឋខ្មែរ

- ទារកដែលកើតពីឪពុក និងម្តាយជាប្រជាពលរដ្ឋខ្មែរ ខ្នង់សញ្ជាតិរបស់អ្នកកើតត្រូវកត់ត្រាសញ្ជាតិ "ខ្មែរ"។
- ទារកដែលកើតពីឪពុក ឬម្តាយដែលម្នាក់ជាប្រជាពលរដ្ឋខ្មែរ ខ្នង់សញ្ជាតិរបស់អ្នកកើតត្រូវកត់ត្រាសញ្ជាតិ "ខ្មែរ"។
- សញ្ជាតិឪពុក និង/ឬម្តាយ ត្រូវកត់ត្រាតាមឯកសារបញ្ជាក់អំពីសញ្ជាតិ ដូចមានចែងក្នុងប្រការ២៥ ចំណុច "ក" នៃប្រកាសនេះ។

ខ- សម្រាប់ជនបរទេស

- ទារកដែលកើតពីឪពុក និង/ឬម្តាយជាជនបរទេសដែលមានសញ្ជាតិដូចគ្នា ឬខុសគ្នា ឬមិនអាចកំណត់សញ្ជាតិបាន ខ្នង់សញ្ជាតិរបស់អ្នកកើតត្រូវកត់ត្រា "**មិនអាចកំណត់បាន**"។
- សញ្ជាតិរបស់ឪពុក និង/ឬម្តាយជាជនបរទេស ត្រូវកត់ត្រាតាមឯកសារបញ្ជាក់អំពីសញ្ជាតិ ដូចមានចែងក្នុងប្រការ២៥ ចំណុច "ខ" នៃប្រកាសនេះ។
- ករណីឪពុក និង/ឬម្តាយជាជនបរទេសដែលពុំមានឯកសារបញ្ជាក់អំពីសញ្ជាតិ ដូចមានចែងក្នុងប្រការ២៥ ចំណុច "ខ" នៃប្រកាសនេះ ត្រូវកត់ត្រា "**មិនអាចកំណត់បាន**"។

ប្រការ២៩.- ឈ្មោះរបស់អ្នកកើត

ឪពុកនិង/ឬម្តាយ ឬអាណាព្យាបាល ឬអ្នករាយការណ៍ ជាអ្នកដាក់ឈ្មោះរបស់អ្នកកើត។

ករណីទារកដែលរើសបាន មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ជាអ្នកកំណត់ឈ្មោះអ្នកកើត។

ការដាក់ឈ្មោះអ្នកកើត មិនត្រូវធ្វើឱ្យប៉ះពាល់ដល់កិត្តិយសផ្ទាល់ខ្លួន ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អឡើយ។

ផ្នែកទី៥
ការចុះបញ្ជីកំណើតរស់សម្រាប់ប្រជាពលរដ្ឋខ្មែរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរស់នៅបរទេសដែលពុំមានឯកសារគ្រប់គ្រាន់ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់

ប្រការ៣០.- ទម្រង់ និងព័ត៌មានពាក្យសុំចុះបញ្ជីកំណើតរស់

ទម្រង់ និងព័ត៌មានពាក្យសុំចុះបញ្ជីកំណើតរស់ សម្រាប់ប្រជាពលរដ្ឋខ្មែរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរស់នៅបរទេសដែលពុំមានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ ត្រូវអនុវត្តដូចបានកំណត់នៅក្នុងប្រការ១៩ នៃប្រកាសនេះ។

ប្រការ៣១.- ទីកន្លែង និងការដាក់ពាក្យសុំចុះបញ្ជីកំណើតរស់

១. ប្រជាពលរដ្ឋខ្មែររស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពុំមានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ ត្រូវដាក់ពាក្យសុំចុះបញ្ជីកំណើតរស់នៅទីកន្លែងណាមួយដូចខាងក្រោម៖

- រដ្ឋបាលឃុំ សង្កាត់ ដែលអ្នករាយការណ៍ស្នាក់នៅ ឬ
- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ។

២. ប្រជាពលរដ្ឋខ្មែរ រស់នៅបរទេសដែលពុំមានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ ត្រូវដាក់ពាក្យសុំចុះបញ្ជីកំណើតរស់នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ។

ប្រការ៣២.-ការកំណត់អត្តសញ្ញាណប្រជាពលរដ្ឋខ្មែររស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពុំមានឯកសារគ្រប់គ្រាន់ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ នៅរដ្ឋបាល ឃុំ សង្កាត់

ការចុះបញ្ជីកំណើតរស់សម្រាប់ប្រជាពលរដ្ឋខ្មែររស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពុំមានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ ត្រូវសម្រេចដោយក្រុមការងារកំណត់អត្តសញ្ញាណឃុំ សង្កាត់ ដែលដឹកនាំដោយមេឃុំ ឬចៅសង្កាត់។ សមាសភាពក្រុមការងារកំណត់អត្តសញ្ញាណឃុំ សង្កាត់ រួមមាន (១) មេឃុំ ឬចៅសង្កាត់ (២) នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ (៣)ស្មៀនឃុំ សង្កាត់ និង (៤) មេភូមិនៃទីកន្លែងដែលសាមីជនស្នាក់នៅ។ ក្រុមការងារកំណត់អត្តសញ្ញាណឃុំ សង្កាត់ មានភារកិច្ចដូចតទៅ៖

- សម្ភាស និងធ្វើកំណត់ហេតុសាកសួរអ្នកស្នើសុំ ដោយមានការចូលរួមពីសាក្សី ១រូប ជាពលរដ្ឋខ្មែរដែលមានអត្តសញ្ញាណច្បាស់លាស់ ដើម្បីពិនិត្យ វាយតម្លៃ និងកំណត់អត្តសញ្ញាណអ្នកស្នើសុំនោះ ថាជាពលរដ្ឋខ្មែរ ឬមិនមែនជាពលរដ្ឋខ្មែរ
- ក្នុងករណីចាំបាច់ ក្រុមការងារកំណត់អត្តសញ្ញាណ អាចសាកសួរព័ត៌មានបន្ថែម ពីសាច់ញាតិអ្នកជិតខាង ឬចាស់ព្រឹទ្ធាចារ្យ ដើម្បីកំណត់អត្តសញ្ញាណ
- ក្រុមការងារកំណត់អត្តសញ្ញាណ ត្រូវធ្វើកំណត់ហេតុសាកសួរចំនួន ២ច្បាប់ ដោយ ១(មួយ) ច្បាប់រក្សាទុកនៅរដ្ឋបាលឃុំ សង្កាត់ និង១(មួយ)ច្បាប់ទៀត រក្សាទុកនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- ក្នុងករណីពិនិត្យឃើញថា អ្នកស្នើសុំជាពលរដ្ឋខ្មែរពិតប្រាកដ ក្រុមការងារកំណត់អត្តសញ្ញាណត្រូវសម្រេចឱ្យមន្ត្រីអត្រានុកូលដ្ឋាន ចុះបញ្ជីកំណើត និងផ្តល់សំបុត្រកំណើតជូនអ្នកស្នើសុំ។ កំណត់ហេតុសាកសួរបញ្ជាក់អត្តសញ្ញាណនេះ ត្រូវកំណត់យកជាឯកសារភ្ជាប់សម្រាប់ចុះបញ្ជីកំណើតរស់
- ក្នុងករណីមិនអាចកំណត់អត្តសញ្ញាណបានថាជាពលរដ្ឋខ្មែរ ក្រុមការងារកំណត់អត្តសញ្ញាណត្រូវបដិសេធអំពីការចុះបញ្ជីកំណើតរស់ និងជូនដំណឹងអំពីការបដិសេធនេះទៅសាមីជន តាមនីតិវិធីកំណត់។

ប្រការ៣៣.- នីតិវិធីនៃការចុះបញ្ជីកំណើតរស់សម្រាប់ប្រជាពលរដ្ឋខ្មែរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពុំមានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ នៅរដ្ឋបាលឃុំ សង្កាត់

បន្ទាប់ពីទទួលបានពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់សម្រាប់ចុះបញ្ជីកំណើតរស់ដែលជាកំណត់ហេតុសាកសួរអត្តសញ្ញាណរបស់ក្រុមការងារកំណត់អត្តសញ្ញាណឃុំ សង្កាត់ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

- កត់ត្រាព័ត៌មានពាក់ព័ន្ធនឹងកំណើតរស់ទៅក្នុងពាក្យសុំនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន
- បោះពុម្ពពាក្យសុំចុះបញ្ជីកំណើតរស់ឱ្យអ្នករាយការណ៍ផ្តិតស្នាមម្រាមដៃ
- ស្កែនពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច និងមន្ត្រីទទួលពាក្យត្រូវអនុវត្តបែបបទនិងនីតិវិធីដូចបានកំណត់ក្នុងចំណុច២ ដល់ចំណុច៦ ប្រការ២៧ នៃប្រកាសនេះ។

ប្រការ៣៤.- ការកំណត់អត្តសញ្ញាណប្រជាពលរដ្ឋខ្មែរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរស់នៅបរទេស ដែលពុំមានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ

ការចុះបញ្ជីកំណើតរស់សម្រាប់ប្រជាពលរដ្ឋខ្មែរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរស់នៅបរទេសដែលពុំមានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ ត្រូវសម្រេចដោយអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ បន្ទាប់ពីទទួលបានយោបល់ពីក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិ។

សមាសភាពក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិរួមមាន (១) អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ១រូប (២) ប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន (៣) ប្រធាននាយកដ្ឋានស្ថិតិប្រជាពលរដ្ឋ និង(៤) ប្រធាននាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ ក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិ មានភារកិច្ចដូចខាងក្រោម៖

- សម្ភាស និងធ្វើកំណត់ហេតុសាកសួរអ្នកស្នើសុំ ដោយមានការចូលរួមពីសាក្សី ១រូប ជាពលរដ្ឋខ្មែរដែលមានអត្តសញ្ញាណច្បាស់លាស់ ដើម្បីពិនិត្យ វាយតម្លៃ និងកំណត់អត្តសញ្ញាណអ្នកស្នើសុំនោះថាជាពលរដ្ឋខ្មែរ ឬមិនមែនជាពលរដ្ឋខ្មែរ
- ក្នុងករណីចាំបាច់ ក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិ អាចធ្វើការស្រាវជ្រាវសាកសួរព័ត៌មានបន្ថែម ដើម្បីកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់
- ក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិ ត្រូវធ្វើកំណត់ហេតុសាកសួរចំនួន បីច្បាប់ ដោយ ១ (មួយ)ច្បាប់ រក្សាទុកនៅក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិ និង១(មួយ) ច្បាប់ទៀត រក្សាទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន

- ក្នុងករណីពិនិត្យឃើញថា អ្នកស្នើសុំជាពលរដ្ឋខ្មែរពិតប្រាកដ ក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិត្រូវសម្រេចចុះបញ្ជីកំណើតរស់ និងផ្តល់សំបុត្រកំណើតរស់ជូនអ្នកស្នើសុំ។ កំណត់ហេតុសាកសួរបញ្ជាក់អត្តសញ្ញាណនេះ ត្រូវកំណត់យកជាឯកសារភ្ជាប់សម្រាប់ចុះបញ្ជីកំណើតរស់
- ក្នុងករណីមិនអាចកំណត់អត្តសញ្ញាណបានថាជាពលរដ្ឋខ្មែរ ក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិ ត្រូវបដិសេធអំពីការចុះបញ្ជីកំណើតរស់ និងជូនដំណឹងអំពីការបដិសេធនេះទៅសាមីជនតាមនីតិវិធីកំណត់។

ប្រការ៣៥.- នីតិវិធីនៃការចុះបញ្ជីកំណើតរស់សម្រាប់ប្រជាពលរដ្ឋខ្មែរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរស់នៅបរទេសដែលពុំមានឯកសារគ្រប់គ្រាន់ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ

១. បន្ទាប់ពីទទួលបានពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់សម្រាប់ចុះបញ្ជីកំណើតរស់ដែលជាកំណត់ហេតុសាកសួរអត្តសញ្ញាណរបស់ក្រុមការងារកំណត់អត្តសញ្ញាណថ្នាក់ជាតិ មន្ត្រីទទួលពាក្យនៅនាយកដ្ឋានអត្រានុកូលដ្ឋាន ត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

- កត់ត្រាព័ត៌មានពាក់ព័ន្ធនឹងកំណើតរស់ទៅក្នុងពាក្យសុំនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន
- បោះពុម្ពពាក្យសុំចុះបញ្ជីកំណើតរស់ឱ្យអ្នករាយការណ៍ផ្តិតស្នាមម្រាមដៃ
- ស្កែនពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

២. មន្ត្រីទទួលបន្ទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ជាមួយពាក្យសុំចុះបញ្ជីកំណើតរស់និងឯកសារភ្ជាប់។ បើពិនិត្យឃើញថាត្រឹមត្រូវហើយ ត្រូវលើកយោបល់ស្នើសុំការពិនិត្យសម្រេចទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវសម្រេចចុះបញ្ជីកំណើតរស់នៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល។

៤. មន្ត្រីទទួលបន្ទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន ត្រូវបោះពុម្ពបញ្ជីកំណើតរស់ចំនួន ១(មួយ)ច្បាប់ និងសំបុត្រកំណើតចំនួន ១(មួយ)ច្បាប់ ដើម្បីឱ្យអ្នករាយការណ៍ ផ្តិតស្នាមម្រាមដៃលើបញ្ជីកំណើតរស់មុននឹងដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិចុះហត្ថលេខា និងបោះត្រា រួចប្រគល់សំបុត្រកំណើតច្បាប់ដើមជូនអ្នករាយការណ៍។

៥. ករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មិនអាចចុះបញ្ជីកំណើតរស់ក្នុងពេលដាក់ពាក្យសុំបាន មន្ត្រីទទួលពាក្យនៅនាយកដ្ឋានអត្រានុកូលដ្ឋាន ត្រូវចេញបង្កាន់ដៃចំនួន ២ច្បាប់ ដោយ ១(មួយ)ច្បាប់ ជូនអ្នករាយការណ៍ និង១(មួយ)ច្បាប់ ទៀតរក្សាទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន។ ករណីនេះ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវពិនិត្យ សម្រេចចុះបញ្ជីកំណើតរស់ និងចេញសំបុត្រកំណើតច្បាប់ដើមចំនួន ១(មួយ)ច្បាប់ ជូនអ្នករាយការណ៍មិនឱ្យលើសរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

៦. មន្ត្រីទទួលពាក្យនៅនាយកដ្ឋានអត្រានុកូលដ្ឋាន ត្រូវស្នើនបញ្ជីកំណើតរស់ និងសំបុត្រកំណើត ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកបញ្ជីកំណើតរស់ ពាក្យសុំចុះបញ្ជីកំណើតរស់ និងឯកសារភ្ជាប់នៅនាយកដ្ឋានអត្រានុកូលដ្ឋាន។

ផ្នែកទី៦
ការជាសង្ឃឹនក្នុងការចុះបញ្ជីកំណើតរស់ និងការចុះបញ្ជីកំណើតរស់ចល័ត

ប្រការ៣៦.- ការជាសង្ឃឹនរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់

ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ បានទទួលការជូនដំណឹងអំពីកំណើតរស់ពីមូលដ្ឋានសុខាភិបាល ឬបានទទួលការរាយការណ៍អំពីកំណើតរស់ពីមេភូមិ ឬពីអាជ្ញាធរពាក់ព័ន្ធ ឬពីប្រភពផ្សេងទៀត ហើយអ្នករាយការណ៍មិនទាន់បានមកស្នើសុំចុះបញ្ជីកំណើតរស់ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់នៃទីកន្លែងដែលអ្នករាយការណ៍ស្នាក់នៅ ត្រូវជាសង្ឃឹនដល់អ្នករាយការណ៍ឱ្យមកចុះបញ្ជីកំណើតរស់ ក្រោយរយៈពេល ១០(ដប់)ថ្ងៃ បន្ទាប់ពីកំណើតរស់បានកើតឡើង រហូតដល់អ្នករាយការណ៍បានមកចុះបញ្ជីកំណើតរស់។

ប្រការ៣៧.- ការចុះបញ្ជីកំណើតរស់ចល័ត

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជាអាចចុះបញ្ជីកំណើតរស់ចល័តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យការចុះបញ្ជីកំណើតរស់បានគ្រប់គ្នា។

ជំពូកទី៥
ការចុះបញ្ជីមរណភាព
ផ្នែកទី១
អ្នករាយការណ៍អំពីមរណភាព

ប្រការ៣៨.- អ្នករាយការណ៍អំពីមរណភាព

អ្នករាយការណ៍អំពីមរណភាព ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោម៖

ក- សម្រាប់មរណភាពរបស់អនីតិជន
- ម្តាយ ឬឪពុក ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន
- ញាតិជានីតិជនរបស់មរណជន
- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀត ដែលកំណត់ដោយច្បាប់។

ខ- សម្រាប់មរណភាពរបស់នីតិជន
- សហព័ទ្ធរបស់មរណជន
- ញាតិជានីតិជនរបស់មរណជន
- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀត ដែលកំណត់ដោយច្បាប់។

ប្រការ៣៩.- អ្នករាយការណ៍អំពីមរណភាពជាអនីតិជន ឬជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ

ក្នុងករណីមិនមានអ្នករាយការណ៍អំពីមរណភាពដូចបានកំណត់ក្នុងប្រការ៣៨ ខាងលើនេះ អ្នករាយការណ៍អំពីមរណភាពជាអនីតិជន ត្រូវបានកំណត់ដូចខាងក្រោម៖

ក- អនីតិជនមានអាយុចាប់ពី ១៥ឆ្នាំឡើង អាចរាយការណ៍អំពីមរណភាពបាន។

ខ- អនីតិជនមានអាយុក្រោម ១៥ឆ្នាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរាយការណ៍ជំនួសឱ្យអនីតិជននោះ។

ក្នុងករណីដែលអ្នករាយការណ៍ជាជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅត្រូវជើរតួជាអ្នករាយការណ៍ជំនួសឱ្យជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅនោះ។

ផ្នែកទី២
ទម្រង់ បែបបទ និងការដាក់ពាក្យសុំចុះបញ្ជីមរណភាព

ប្រការ៤០.- ទម្រង់ និងព័ត៌មានពាក្យសុំចុះបញ្ជីមរណភាព

ព័ត៌មាននៅក្នុងពាក្យសុំចុះបញ្ជីមរណភាព មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់មរណជន
- ភេទរបស់មរណជន
- សញ្ជាតិរបស់មរណជន
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់មរណជន
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលមរណជនទទួលមរណភាព
- នាមត្រកូល និងនាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នករាយការណ៍។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃពាក្យសុំចុះបញ្ជីមរណភាពជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី១៤** នៃប្រកាសនេះ។

ករណីពាក្យសុំចុះបញ្ជីមរណភាពក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្លឹងទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៤១.- ទីកន្លែង និងការដាក់ពាក្យសុំចុះបញ្ជីមរណភាព

ការដាក់ពាក្យសុំចុះបញ្ជីមរណភាព ត្រូវអនុវត្តតាមការកំណត់ដូចខាងក្រោម៖

១. ក្នុងករណីមរណភាពដែលបានកើតឡើងនៅព្រះរាជាណាចក្រកម្ពុជា អ្នករាយការណ៍អាចដាក់ពាក្យសុំនៅរដ្ឋបាលឃុំ សង្កាត់ ដែលមរណភាពបានកើតឡើង ឬរដ្ឋបាលឃុំ សង្កាត់ ដែលមរណជនស្នាក់នៅ។

២. ក្នុងករណីមរណភាពដែលបានកើតឡើងនៅបរទេស អ្នករាយការណ៍អាចដាក់ពាក្យសុំនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ដែលមរណភាពបានកើតឡើង។ ករណីស្ថានស្ថានតំណាង ឬពុំអាចរាយការណ៍ ឬពុំមានលទ្ធភាពរាយការណ៍អំពីមរណភាព អ្នករាយការណ៍ត្រូវដាក់ពាក្យសុំនៅរដ្ឋបាលឃុំ សង្កាត់ ដែលមរណជនបានស្នាក់នៅ ឬអ្នករាយការណ៍ស្នាក់នៅក្រោយពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជា។

៣. ក្នុងករណីដែលមានសាកសពមិនស្គាល់អត្តសញ្ញាណ អ្នកដែលឃើញសាកសពនោះ ត្រូវផ្តល់ព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការស៊ើបអង្កេត។ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងការស៊ើបអង្កេត ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ដើម្បីចុះបញ្ជីមរណភាពរបស់សាកសពដែលមិនស្គាល់អត្តសញ្ញាណ។

៤. ក្នុងករណីមានការប្រកាសរបស់តុលាការអំពីការបាត់ខ្លួន អ្នករាយការណ៍អាចដាក់ពាក្យសុំចុះបញ្ជីមរណភាពឱ្យបុគ្គលដែលត្រូវបានចាត់ទុកថាបានទទួលមរណភាពនោះ នៅរដ្ឋបាលឃុំ សង្កាត់ដែលមរណជនស្នាក់នៅ ឬនៅរដ្ឋបាលឃុំ សង្កាត់ដែលអ្នករាយការណ៍ស្នាក់នៅ។

ការដាក់ពាក្យសុំចុះបញ្ជីមរណភាព ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ឬតាមទម្រង់អេឡិចត្រូនិក។

ផ្នែកទី៣
ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីមរណភាព

ប្រការ៤២.- ឯកសារបញ្ជាក់អំពីមរណភាព

ឯកសារបញ្ជាក់អំពីមរណភាព ត្រូវបានកំណត់ដូចខាងក្រោម៖

១. ក្នុងករណីការចុះបញ្ជីមរណភាពក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃដែលមរណភាពបានកើតឡើង អ្នករាយការណ៍ត្រូវផ្តល់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា នូវឯកសារដូចខាងក្រោម៖

- លិខិតជូនដំណឹងអំពីមរណភាពចេញដោយមូលដ្ឋានសុខាភិបាល ឬ
- សំបុត្រមរណភាព ឬកស្តុតាងអំពីមរណភាពផ្សេងទៀតពីប្រទេសដែលមរណភាពបានកើតឡើង។

២. ក្នុងករណីការចុះបញ្ជីមរណភាពក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ អ្នករាយការណ៍ត្រូវផ្តល់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា នូវឯកសារដូចខាងក្រោម៖

ក- ឯកសារបញ្ជាក់អំពីមរណភាព

- លិខិតជូនដំណឹងអំពីមរណភាពចេញដោយមូលដ្ឋានសុខាភិបាល ឬសំបុត្រមរណភាព ឬកស្តុតាងអំពីមរណភាពផ្សេងទៀតពីប្រទេសដែលមរណភាពបានកើតឡើង ឬ
- កស្តុតាងផ្សេងទៀតដែលអាចបញ្ជាក់អំពីមរណភាព និង

ខ- ការបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។



៣. ក្នុងករណីការចុះបញ្ជីមរណភាពក្រោយផុតរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ អ្នករាយការណ៍ត្រូវផ្តល់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា នូវឯកសារដូចខាងក្រោម៖

ក- ឯកសារបញ្ជាក់អំពីមរណភាព

- លិខិតជូនដំណឹងអំពីមរណភាពចេញដោយមូលដ្ឋានសុខាភិបាល ឬ
- សំបុត្រមរណភាព ឬកស្តុតាងអំពីមរណភាពផ្សេងទៀតពីប្រទេសដែលមរណភាពបានកើតឡើង ឬ
- កស្តុតាងផ្សេងទៀតដែលអាចបញ្ជាក់អំពីមរណភាព និង

ខ- ការបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ និង

គ- ការធានាអះអាងរបស់សាក្សី ១(មួយ)រូប ជានីតិជន ជាប្រជាពលរដ្ឋខ្មែរ ឬជនបរទេសរស់នៅស្របច្បាប់ ដែលដឹងអំពីមរណភាពចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយភ្ជាប់ឯកសារអត្តសញ្ញាណមកជាមួយ។

ប្រការ៤៣.- ឯកសារអត្តសញ្ញាណរបស់មរណជន

ឯកសារអត្តសញ្ញាណរបស់មរណជន ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សម្រាប់ប្រជាពលរដ្ឋខ្មែរ

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត និង/ឬ
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬ
- លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល ឬ
- ឯកសារអត្តសញ្ញាណផ្សេងទៀត ប្រសិនបើមាន។

ខ- សម្រាប់ជនបរទេស

- សំបុត្រកំណើត ឬ
- លិខិតឆ្លងដែន ឬ
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត ឬ
- ឯកសារអត្តសញ្ញាណផ្សេងទៀត ប្រសិនបើមាន។

ប្រការ៤៤.- ឯកសារអត្តសញ្ញាណរបស់អ្នករាយការណ៍

ឯកសារអត្តសញ្ញាណរបស់អ្នករាយការណ៍ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សម្រាប់ប្រជាពលរដ្ឋខ្មែរ

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬ
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬ
- លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល ឬ
- ឯកសារអត្តសញ្ញាណផ្សេងទៀត ប្រសិនបើមាន។

ខ- សម្រាប់ជនបរទេស

- សំបុត្រកំណើត ឬ
- លិខិតឆ្លងដែន ឬ

- បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត ឬ
- ឯកសារអត្តសញ្ញាណផ្សេងទៀតចេញដោយប្រទេសសាមី ឬស្ថានតំណាង។

ប្រការ៤៥.- ឯកសារបញ្ជាក់អំពីការស្នាក់នៅរបស់មរណជន

ឯកសារបញ្ជាក់អំពីការស្នាក់នៅរបស់មរណជន ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬ

ខ- ឯកសារផ្សេងទៀត ដែលបញ្ជាក់អំពីការស្នាក់នៅ។

ផ្នែកទី៤
នីតិវិធីនៃការចុះបញ្ជីមរណភាព

ប្រការ៤៦.- ដំណើរការចុះបញ្ជីមរណភាព និងចេញលិខិតអនុញ្ញាតឱ្យបូជា ឬបញ្ចុះសពនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ការចុះបញ្ជីមរណភាព និងការចេញលិខិតអនុញ្ញាតឱ្យបូជា ឬបញ្ចុះសពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំចុះបញ្ជីមរណភាព និងឯកសារភ្ជាប់សម្រាប់ចុះបញ្ជីមរណភាពដែលត្រឹមត្រូវនិងគ្រប់គ្រាន់ហើយ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តដូចខាងក្រោម៖

- កត់ត្រាព័ត៌មានពាក់ព័ន្ធនឹងមរណជនទៅក្នុងពាក្យសុំនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន
- ករណីអ្នករាយការណ៍មានលិខិតជូនដំណឹងអំពីមរណភាពចេញ ដោយមូលដ្ឋានសុខាភិបាលត្រូវរៀបបញ្ចូលលេខសម្គាល់ ឬស្កែនលេខកូដឆ្លើយតបហ័ស (QR) នៃលិខិតជូនដំណឹងអំពីមរណភាព និងបញ្ចូលព័ត៌មាននោះ ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន
- បោះពុម្ពពាក្យសុំចុះបញ្ជីមរណភាពឱ្យអ្នករាយការណ៍ផ្តិតស្នាមម្រាមដៃ
- ស្កែនពាក្យសុំចុះបញ្ជីមរណភាព និងឯកសារភ្ជាប់ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

២. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានជាមួយពាក្យសុំចុះបញ្ជីមរណភាព និងឯកសារភ្ជាប់។ បើពិនិត្យឃើញថាត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំសង្កាត់ ត្រូវស្នើសុំបិទលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល និងសម្រេចចុះបញ្ជីមរណភាពនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

៣. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ត្រូវបោះពុម្ពបញ្ជីមរណភាពចំនួន ១(មួយ)ច្បាប់ សំបុត្រមរណភាពចំនួន ១(មួយ)ច្បាប់ និងលិខិតអនុញ្ញាតឱ្យបូជា ឬបញ្ចុះសពចំនួន ១(មួយ)ច្បាប់ ដើម្បីឱ្យអ្នករាយការណ៍ផ្តិតស្នាមម្រាមដៃលើបញ្ជីមរណភាព មុននឹងដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ចុះហត្ថលេខា និងបោះត្រា។

៤. ករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មិនអាចចុះបញ្ជីនៅពេលដាក់ពាក្យសុំបាន មន្ត្រីទទួលពាក្យសុំនៅរដ្ឋបាលឃុំ សង្កាត់ ត្រូវចេញបង្កាន់ដៃចំនួន ២(ពីរ)ច្បាប់ ដោយ ១(មួយ)ច្បាប់ ជូនអ្នករាយការណ៍ និង ១(មួយ)ច្បាប់ ទៀតរក្សាទុកនៅរដ្ឋបាលឃុំ សង្កាត់។ ករណីនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញលិខិតអនុញ្ញាតឱ្យបូជា ឬបញ្ចុះសពឱ្យទាន់ពេលវេលាតាមការស្នើសុំ និងត្រូវពិនិត្យសម្រេចចុះបញ្ជីមរណភាព និងចេញសំបុត្រមរណភាពច្បាប់ដើម ជូនអ្នករាយការណ៍មិនឱ្យលើសរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

៥. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ត្រូវស្នែនបញ្ជីមរណភាព សំបុត្រមរណភាព និងលិខិតអនុញ្ញាតឱ្យបូជា ឬបញ្ចុះសព ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកបញ្ជីមរណភាព និងពាក្យសុំចុះបញ្ជីមរណភាព ព្រមទាំងឯកសារភ្ជាប់នៅរដ្ឋបាលឃុំ សង្កាត់។

ព័ត៌មានអប្បបរមាដែលចាំបាច់សម្រាប់ការចុះបញ្ជីមរណភាពរួមមាន ឈ្មោះ ភេទ ថ្ងៃខែឆ្នាំ និងទីកន្លែងដែលមរណជនទទួលមរណភាព។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មិនត្រូវបដិសេធការចុះបញ្ជីមរណភាពទេ ប្រសិនបើអ្នករាយការណ៍មិនអាចផ្តល់ព័ត៌មានផ្សេងទៀតនៅក្នុងពាក្យសុំចុះបញ្ជីមរណភាព។

ទម្រង់ និងព័ត៌មានលិខិតអនុញ្ញាតឱ្យបូជា ឬបញ្ចុះសព ជា**ឧបសម្ព័ន្ធទី១៥** នៃប្រកាសនេះ។

ប្រការ៤៧.- ដំណើរការចុះបញ្ជីមរណភាពនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាដៅបរទេស

ការចុះបញ្ជីមរណភាពនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំចុះបញ្ជីមរណភាព និងឯកសារភ្ជាប់សម្រាប់ចុះបញ្ជីមរណភាពដែលត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ មន្ត្រីទទួលពាក្យនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តដូចខាងក្រោម៖

- កត់ត្រាព័ត៌មានពាក់ព័ន្ធនឹងមរណជនទៅក្នុងពាក្យសុំនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន
- បោះពុម្ពពាក្យសុំចុះបញ្ជីមរណភាពឱ្យអ្នករាយការណ៍ផ្តិតស្នាមម្រាមដៃ
- ស្នែនពាក្យសុំចុះបញ្ជីមរណភាព និងឯកសារភ្ជាប់ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

២. មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ជាមួយពាក្យសុំចុះបញ្ជីមរណភាព និងឯកសារភ្ជាប់។ បើពិនិត្យឃើញថាត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំបិទលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល និងសម្រេចចុះបញ្ជីមរណភាពនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

៣. មន្ត្រីទទួលពាក្យនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវបោះពុម្ពបញ្ជីមរណភាពចំនួន ១(មួយ)ច្បាប់ និងសំបុត្រមរណភាពចំនួន ១(មួយ)ច្បាប់ ដើម្បីឱ្យអ្នករាយការណ៍ផ្តិតស្នាមម្រាមដៃលើបញ្ជីមរណភាព មុននឹងដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខានិងបោះត្រា។

៤. ករណីមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា មិនអាចចុះបញ្ជីនៅពេលដាក់ពាក្យសុំបាន មន្ត្រីទទួលពាក្យសុំនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវចេញបង្កាន់ដៃចំនួន ២(ពីរ)ច្បាប់ ដោយ ១(មួយ)ច្បាប់ ជូនអ្នករាយការណ៍ និង ១(មួយ)ច្បាប់ ទៀតត្រូវរក្សាទុកនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។ ករណីនេះ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យសម្រេចចុះបញ្ជីមរណភាព និងចេញសំបុត្រមរណភាពច្បាប់ដើម ជូនអ្នករាយការណ៍មិនឱ្យលើសពីរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

៥. មន្ត្រីទទួលពាក្យនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវស្នើសុំបញ្ជីមរណភាព និងសំបុត្រមរណភាព ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកបញ្ជីមរណភាព និងពាក្យសុំចុះបញ្ជីមរណភាព ព្រមទាំងឯកសារភ្ជាប់នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។

ព័ត៌មានអប្បបរមាដែលចាំបាច់សម្រាប់ការចុះបញ្ជីមរណភាពរួមមាន ឈ្មោះ ភេទ ថ្ងៃខែឆ្នាំ និងទីកន្លែងដែលមរណជនទទួលមរណភាព។ មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវបដិសេធការចុះបញ្ជីមរណភាពទេ ប្រសិនបើអ្នករាយការណ៍មិនអាចផ្តល់ព័ត៌មានផ្សេងទៀតនៅក្នុងពាក្យសុំចុះបញ្ជីមរណភាព។

ផ្នែកទី៥
ការជាសាក្សីក្នុងការចុះបញ្ជីមរណភាព និងការចុះបញ្ជីមរណភាពចល័ត

ប្រការ៤៨.- ការជាសាក្សីអ្នករាយការណ៍

បន្ទាប់ពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់បានទទួលការជូនដំណឹងអំពីមរណភាពពីមូលដ្ឋានសុខាភិបាល ឬបានទទួលការរាយការណ៍អំពីមរណភាពពីមេភូមិ ឬអាជ្ញាធរពាក់ព័ន្ធ ឬប្រភពផ្សេងទៀត ហើយអ្នករាយការណ៍មិនទាន់បានមកស្នើសុំចុះបញ្ជីមរណភាព មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ នៃទីកន្លែងដែលមរណជនស្នាក់នៅត្រូវដាស់តឿនអ្នករាយការណ៍ ឱ្យមកចុះបញ្ជីមរណភាពក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃយ៉ាងយូរ បន្ទាប់ពីមរណភាពបានកើតឡើង រហូតដល់អ្នករាយការណ៍បានមកចុះបញ្ជីមរណភាព។

ប្រការ៤៩.- ការចុះបញ្ជីមរណភាពចល័ត

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាអាចចុះបញ្ជីមរណភាពចល័តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យការចុះបញ្ជីមរណភាពបានគ្រប់គ្នា។

ជំពូកទី៦
ការចុះបញ្ជីអាពាហ៍ពិពាហ៍
ផ្នែកទី១
ទម្រង់ បែបបទ និងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ប្រការ៥០.- ទម្រង់ និងព័ត៌មានពាក្យសុំរៀបអាពាហ៍ពិពាហ៍

ព័ត៌មានចាំបាច់នៅក្នុងពាក្យសុំរៀបអាពាហ៍ពិពាហ៍ មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់បុរស និងនារី

- សញ្ជាតិរបស់បុរស និងនារី
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់បុរស និងនារី
- ទីកន្លែងកំណើតរបស់បុរស និងនារី
- លំនៅឋានបច្ចុប្បន្នរបស់បុរស និងនារី
- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់បុរស និងនារី (ប្រសិនបើមាន)
- នាមត្រកូល និងនាមខ្លួនឪពុកម្តាយខាងបុរស និងនារី
- សញ្ជាតិរបស់ឪពុកម្តាយខាងបុរស និងនារី
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុកម្តាយខាងបុរស និងនារី
- លំនៅឋានបច្ចុប្បន្នរបស់ឪពុកម្តាយខាងបុរស និងនារី។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃពាក្យសុំរៀបអាពាហ៍ពិពាហ៍ជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី១៦** នៃប្រកាសនេះ។

ករណីពាក្យសុំរៀបអាពាហ៍ពិពាហ៍ក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្ទង់ទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៥១.- ទីកន្លែង និងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

បុរស និងនារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅទីកន្លែងដូចបានកំណត់ខាងក្រោម៖

ក- ប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋខ្មែរ ឬជនបរទេសនិងជនបរទេស ដែលចូលឬស្នាក់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃរដ្ឋបាលឃុំ សង្កាត់ ដែលបុរសនារីនោះរស់នៅ។

ខ- ប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋខ្មែរ ដែលរស់នៅស្របច្បាប់នៅបរទេស ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា នៅបរទេសដែលសាមីជនរស់នៅ។

ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។

ផ្នែកទី២
ឯកសារភ្ជាប់សម្រាប់ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ប្រការ៥២.- ឯកសារភ្ជាប់សម្រាប់ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ឯកសារភ្ជាប់សម្រាប់ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវបានកំណត់ដូចខាងក្រោម៖



១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់ឯកសារដូចមានៈ
   ក- អាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋខ្មែរ

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត និង/ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬឯកសារបញ្ជាក់អំពីការស្នាក់នៅផ្សេងទៀតចំពោះប្រជាពលរដ្ឋខ្មែរនៅបរទេស
- ការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬសេចក្តីសម្រេចរបស់តុលាការ (ករណីអនីតិជន)។

ខ- អាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេស

- លិខិតឆ្លងដែន និង/ឬបណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត ដែលមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយប្រទេសសាមី ឬស្ថានតំណាងនៃប្រទេសសាមី
- សៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់។

២. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋខ្មែរ នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត និង/ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ
- ការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬសេចក្តីសម្រេចរបស់តុលាការ(ករណីអនីតិជន)។

អាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរ និងជនបរទេស ត្រូវអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តដោយឡែក។

ផ្នែកទី៣
នីតិវិធីនៃការចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍

ប្រការ៥៣.- ដំណើរការនៃការចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍

ការចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងឯកសារភ្ជាប់សម្រាប់ការណាក៏ពាក្យសុំរៀបអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តការកិច្ចដូចខាងក្រោម៖

- កត់ត្រាព័ត៌មានពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ ទៅក្នុងពាក្យសុំនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន
- បោះពុម្ពពាក្យសុំរៀបអាពាហ៍ពិពាហ៍ឱ្យបុរស និងនារីផ្តិតស្នាមម្រាមដៃ
- ស្នែនពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងឯកសារភ្ជាប់ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

២. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ជាមួយពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងឯកសារភ្ជាប់។ បើពិនិត្យឃើញថាត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវពិនិត្យសម្រេច នៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានលើបណ្ណប្រកាសអាពាហ៍ពិពាហ៍។

៣. ករណីការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ត្រូវបោះពុម្ពបណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ៤(បួន)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ចុះហត្ថលេខា និងបោះត្រា។ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ត្រូវប្រគល់បណ្ណប្រកាសអាពាហ៍ពិពាហ៍ ១(មួយ)ច្បាប់ ទៅបុរស និង១(មួយ)ច្បាប់ទៀតទៅនារី ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដើម្បីបិទផ្សាយជាសាធារណៈនៅតាមលំនៅឋានរៀងៗខ្លួន និងចំនួន ២(ពីរ)ច្បាប់ទៀតបិទផ្សាយជាសាធារណៈនៅរដ្ឋបាលឃុំ សង្កាត់នៃលំនៅឋានរបស់បុរស និងនារី។

៤. ករណីការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសមន្ត្រីទទួលពាក្យនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវបោះពុម្ពបណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ៣(បី)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខា និងបោះត្រា។ មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រគល់បណ្ណប្រកាសអាពាហ៍ពិពាហ៍ ១(មួយ)ច្បាប់ ទៅបុរស និង ១(មួយ)ច្បាប់ទៀតទៅនារី ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍និង ១(មួយ)ច្បាប់ទៀត ត្រូវបិទផ្សាយជាសាធារណៈ នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសដែលមានសមត្ថកិច្ច នៃប្រទេសដែលសាមីជននោះរស់នៅ។

៥. ករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា មិនអាចចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍ក្នុងពេលដាក់ពាក្យសុំបាន មន្ត្រីទទួលពាក្យនៅរដ្ឋបាល ឃុំ សង្កាត់ ឬនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវចេញបង្កាន់ដៃចំនួន ២(ពីរ)ច្បាប់ ដោយ ១(មួយ)ច្បាប់ជូនសាមីខ្លួន និង ១(មួយ)ច្បាប់ទៀតត្រូវរក្សាទុកនៅទីកន្លែងដាក់ពាក្យសុំ។ ករណីនេះ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ និងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាត្រូវពិនិត្យសម្រេចចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍មិនឱ្យលើសពីរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។



៦. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្នែនបណ្ណប្រកាសអាពាហ៍ពិពាហ៍ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកពាក្យសុំរៀបអាពាហ៍-ពិពាហ៍ និងឯកសារភ្ជាប់នៅទីកន្លែងដាក់ពាក្យសុំ។

ផ្នែកទី៤
ទម្រង់ និងព័ត៌មានបណ្ណប្រកាសអាពាហ៍ពិពាហ៍ និងនីតិវិធីនៃការប្រកាសផ្សាយ ជាសាធារណៈអំពីអាពាហ៍ពិពាហ៍

ប្រការ៥៤.- ទម្រង់ និងព័ត៌មាននៃបណ្ណប្រកាសអាពាហ៍ពិពាហ៍

ព័ត៌មាននៅក្នុងបណ្ណប្រកាសអាពាហ៍ពិពាហ៍ មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់បុរស និងនារី
- សញ្ជាតិរបស់បុរស និងនារី
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់បុរស និងនារី
- ទីកន្លែងកំណើតរបស់បុរស និងនារី
- លំនៅឋានបច្ចុប្បន្នរបស់បុរស និងនារី
- នាមត្រកូល និងនាមខ្លួនរបស់ឪពុកម្តាយខាងបុរស និងនារី
- សញ្ជាតិរបស់ឪពុកម្តាយខាងបុរស និងនារី
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុកម្តាយខាងបុរស និងនារី។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃបណ្ណប្រកាសអាពាហ៍ពិពាហ៍ជាក្រដាស និង/ឬអេឡិចត្រូនិក ជាឧបសម្ព័ន្ធទី១៧ នៃប្រកាសនេះ។

ប្រការ៥៥.- ដំណើរការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍

នីតិវិធីនៃការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ដែលធ្វើឡើងនៅរដ្ឋបាលឃុំ សង្កាត់ និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តដូចខាងក្រោម៖

១. ការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍នៅរដ្ឋបាលឃុំ សង្កាត់ មានដំណើរការដូចខាងក្រោម៖

- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយបណ្ណប្រកាសអាពាហ៍ពិពាហ៍ជាប់គ្នាជាបន្តបន្ទាប់នៅរដ្ឋបាលឃុំ សង្កាត់ រយៈពេល ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃសម្រេចឱ្យបិទផ្សាយជាសាធារណៈ។ ប្រសិនបើបុរសឬនារីរស់នៅឃុំ សង្កាត់ផ្សេងគ្នា មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ដែលចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបញ្ជូនបណ្ណប្រកាសអាពាហ៍ពិពាហ៍នោះតាមប្រព័ន្ធអេឡិចត្រូនិក ឬមធ្យោបាយផ្សេងទៀតទៅឃុំ សង្កាត់ នៃលំនៅឋានរបស់បុរស ឬនារី ដើម្បីធ្វើការបិទផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍នោះ។
- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ នៃលំនៅឋានរបស់បុរស និងនារី ត្រូវធានាការបិទផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍នៅលំនៅឋានរបស់បុរស និងនារីជាប់គ្នាជាបន្តបន្ទាប់ក្នុងរយៈពេល ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃសម្រេចឱ្យបិទផ្សាយជាសាធារណៈ មុននឹងអនុញ្ញាតឱ្យបុរស និងនារីចុះបញ្ជីអាពាហ៍ពិពាហ៍។

២. ការប្រកាសផ្សាយជាសាធារណៈ អំពីអាពាហ៍ពិពាហ៍នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសមានដំណើរការដូចខាងក្រោម៖

- មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបិទផ្សាយជាសាធារណៈ អំពីអាពាហ៍ពិពាហ៍នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ជាប់គ្នាជាបន្តបន្ទាប់ក្នុងរយៈពេល ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃសម្រេចឱ្យបិទផ្សាយជាសាធារណៈ។
- មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធានាការបិទផ្សាយបណ្ណប្រកាសអាពាហ៍ពិពាហ៍នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស មុននឹងអនុញ្ញាតឱ្យបុរស និងនារីចុះបញ្ជីអាពាហ៍ពិពាហ៍។

ផ្នែកទី៥
ការប្តឹងជំទាស់អំពីអាពាហ៍ពិពាហ៍

ប្រការ៥៦.- ការប្តឹងជំទាស់អំពីអាពាហ៍ពិពាហ៍

ជនដែលមានផលប្រយោជន៍នៅក្នុងរឿងអាពាហ៍ពិពាហ៍ អាចប្តឹងជំទាស់អំពីអាពាហ៍ពិពាហ៍នេះបានក្នុងរយៈពេល ១០(ដប់)ថ្ងៃ នៃថ្ងៃប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីមានការប្តឹងជំទាស់ មន្ត្រីអត្រានុកូលដ្ឋានដែលទទួលពាក្យបណ្តឹងជំទាស់ ត្រូវជូនដំណឹងទៅបុរស និងនារី ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ អំពីការផ្អាកដំណើរការនៃការរៀបអាពាហ៍ពិពាហ៍។ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានពិនិត្យឃើញថាមិនផ្ទុយនឹងបញ្ញត្តិដូចមានចែងក្នុងមាត្រា៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិផ្សេងទៀតដែលនៅអនុវត្តជាធរមាន មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងទៅអ្នកប្តឹងជំទាស់ អំពីការបដិសេធបណ្តឹង ឬបានដោះស្រាយបណ្តឹងរួចរាល់។

ក្នុងករណីមិនមានការប្តឹងជំទាស់ក្នុងរយៈពេល ១០(ដប់)ថ្ងៃ ឬការប្តឹងជំទាស់នោះ ត្រូវបានដោះស្រាយរួចរាល់ អាពាហ៍ពិពាហ៍អាចធ្វើឡើងគ្រប់ពេលវេលាក្នុងរយៈពេល ៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។

ផ្នែកទី៦
ឯកសារត្រូវប់សម្រាប់ចុះបញ្ជីអាពាហ៍ពិពាហ៍

ប្រការ៥៧.- ឯកសារអត្តសញ្ញាណរបស់បុរស និងនារី

ឯកសារអត្តសញ្ញាណរបស់បុរស និងនារី ត្រូវបានកំណត់ដូចខាងក្រោម៖

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល
- លិខិតឆ្លងដែន ឬបណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន៍ ដែលមានសុពលភាព (ចំពោះជនបរទេស)។

ប្រការ៥៨.- ឯកសារអត្តសញ្ញាណរបស់សាក្សី

ឯកសារអត្តសញ្ញាណរបស់សាក្សីជានីតិជន ត្រូវបានកំណត់ដូចខាងក្រោម៖

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល
- លិខិតឆ្លងដែន ឬបណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត ដែលមានសុពលភាព (ចំពោះជនបរទេស)។

ផ្នែកទី៧
នីតិវិធីនៃការចុះបញ្ជីអាពាហ៍ពិពាហ៍

ប្រការ៥៩.- ដំណើរការចុះបញ្ជីអាពាហ៍ពិពាហ៍

នីតិវិធីនៃការចុះបញ្ជីអាពាហ៍ពិពាហ៍នៅព្រះរាជាណាចក្រកម្ពុជា និងនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តដូចខាងក្រោម៖

១. បុរស និងនារីត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងត្រូវនាំសាក្សីចំនួន ២(ពីរ)រូប ជានីតិជន ដោយភ្ជាប់ឯកសារអត្តសញ្ញាណមកជាមួយ។

២. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានអំពីអត្តសញ្ញាណរបស់បុរស និងនារី ជាមួយព័ត៌មានដែលមាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងកត់ត្រាព័ត៌មានសាក្សីចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ បើពិនិត្យឃើញថាត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវសម្រេចចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

៤. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវបោះពុម្ពបញ្ជីអាពាហ៍ពិពាហ៍ចំនួន ១(មួយ)ច្បាប់ និងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចំនួន ១(មួយ)ច្បាប់ ដើម្បីឱ្យសាមីខ្លួន និងសាក្សីផ្តិតស្នាមម្រាមដៃលើបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា។

៥. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចុះហត្ថលេខា និងបោះត្រាលើបញ្ជី និងសំបុត្រអាពាហ៍ពិពាហ៍ រួចប្រគល់សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមជូនសាមីខ្លួន។



៦. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវស្កែនបញ្ជីអាពាហ៍ពិពាហ៍ សំបុត្រអាពាហ៍ពិពាហ៍ និងឯកសារអត្តសញ្ញាណរបស់សាក្សីចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកបញ្ជីអាពាហ៍ពិពាហ៍ និងឯកសារអត្តសញ្ញាណរបស់សាក្សីនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។

ក្នុងករណីបុរស និងនារីដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ មិនបានមកចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចរំលឹកដោយការជូនដំណឹងទៅបុរស និងនារីនោះបាន។

ក្នុងករណីហួសរយៈពេល ៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ហើយបុរស និងនារីនោះមិនបានមកចុះបញ្ជីអាពាហ៍ពិពាហ៍ បុរស និងនារីត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ឡើងវិញ ដូចបានកំណត់ក្នុងប្រការ៥១ នៃប្រកាសនេះ។

ផ្នែកទី៨
ទម្រង់ បែបបទ និងការដាក់ពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ

ប្រការ៦០.- ទម្រង់ និងព័ត៌មានពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ

ពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយជាក្រដាសត្រូវមានទម្រង់ និងព័ត៌មាន ជាឧបសម្ព័ន្ធទី១៨ នៃប្រកាសនេះ។ ក្នុងករណីពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ តាមទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្ទង់ទិន្នន័យ សម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៦១.- ការដាក់ពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ

សាមីខ្លួនអាចដាក់ពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ នៅរដ្ឋបាលឃុំ សង្កាត់ ឬរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីកន្លែងដែលសាមីខ្លួនស្នាក់នៅ ឬនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសដែលសាមីជននោះរស់នៅ ឬនៅនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬកន្លែងផ្សេងទៀតដែលកំណត់ដោយក្រសួងមហាផ្ទៃ។

ការដាក់ពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។

មន្ត្រីទទួលពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ នៃទីកន្លែងដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវចេញបង្កាន់ដៃជូនសាមីខ្លួន។

ប្រការ៦២.- ឯកសារត្រាប់សម្រាប់ស្នើសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ

ការស្នើសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ ត្រូវភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖

- សំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល និង
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ ឬឯកសារបញ្ជាក់អំពីការស្នាក់នៅផ្សេងទៀត ចំពោះប្រជាពលរដ្ឋខ្មែរនៅបរទេស។

ក្នុងករណីអ្នកស្នើសុំដែលមានចំណងអាពាហ៍ពិពាហ៍ពីមុន ត្រូវភ្ជាប់មកជាមួយនូវសេចក្តីសម្រេចស្តីពីការលែងលះ មោឃភាព ឬលុបចោលអាពាហ៍ពិពាហ៍របស់តុលាការ ឬលិខិតបញ្ជាក់អំពីការលែងលះ មោឃភាព ឬលុបចោលអាពាហ៍ពិពាហ៍ចេញដោយមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ឬសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្រមរណភាពរបស់សហព័ទ្ធ។

ប្រការ៦៣.- ដំណើរការចេញលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ

ការចេញលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ និងឯកសារភ្ជាប់ពី អ្នកស្នើសុំ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ឬនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់ ។

២. ក្នុងករណីព័ត៌មាននៃពាក្យសុំ និងឯកសារភ្ជាប់ គ្រប់គ្រាន់និងត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យ និងមន្ត្រីទទួលបន្ទុក ត្រូវស្វែងរកកំណត់ត្រាអំពីស្ថានភាពអាពាហ៍ពិពាហ៍ នៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ដូចខាងក្រោម៖

ក- ក្នុងករណីឃើញថាមានស្ថានភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ឬមន្ត្រីទទួលបន្ទុកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវបោះពុម្ពលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ និងដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានពិនិត្យសម្រេច។

ខ- ក្នុងករណីឃើញថាពុំមានស្ថានភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬមន្ត្រីទទួលបន្ទុកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវកត់ត្រាព័ត៌មានតាមការអះអាងរបស់សាមីខ្លួន ដោយមានឯកសារបញ្ជាក់អះអាងពីមេភូមិដែលសាមីខ្លួនស្នាក់នៅ ឬអាចធ្វើការស្រាវជ្រាវបន្ថែមតាមការចាំបាច់អំពីស្ថានភាពអាពាហ៍ពិពាហ៍ ហើយត្រូវវាយបញ្ចូលព័ត៌មានទាំងនេះទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ ចំពោះមន្ត្រីទទួលពាក្យនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវកត់ត្រាព័ត៌មានតាមការអះអាងរបស់សាមីខ្លួន និងអាចធ្វើការស្រាវជ្រាវបន្ថែមតាមការចាំបាច់អំពីស្ថានភាពអាពាហ៍ពិពាហ៍ ហើយត្រូវវាយបញ្ចូលព័ត៌មានទាំងនេះទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ មន្ត្រីទទួលពាក្យ និងមន្ត្រីទទួលបន្ទុក ត្រូវបោះពុម្ពលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ និងដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានពិនិត្យសម្រេច។

គ- ក្នុងករណីឃើញថាពុំមានស្ថានភាពលីវ ឬមេម៉ាយ ឬពោះម៉ាយ ប៉ុន្តែមានភ្ជាប់មកជាមួយនូវសេចក្តីសម្រេចស្តីពីការលែងលះ មោឃភាព និងលុបចោលអាពាហ៍ពិពាហ៍ ឬសំបុត្រមរណភាពរបស់សហព័ទ្ធ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ឬមន្ត្រីទទួលបន្ទុកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើបច្ចុប្បន្នភាពស្ថានភាពអាពាហ៍ពិពាហ៍ រួចបោះពុម្ពលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានពិនិត្យសម្រេច។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា និងមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវពិនិត្យសម្រេច មិនឱ្យលើសរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

៤. មន្ត្រីទទួលពាក្យ ត្រូវស្នែនពាក្យសុំ ឯកសារភ្ជាប់ និងលិខិតបញ្ជាក់ភាពនៅលើវ ឬមេម៉ាយ ឬពោះម៉ាយ ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកពាក្យសុំ និងឯកសារភ្ជាប់នៅរដ្ឋបាលឃុំ សង្កាត់ ឬរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនៅនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស រួចប្រគល់លិខិតបញ្ជាក់ភាពនៅលើវ ឬមេម៉ាយ ឬពោះម៉ាយ ជូនសាមីខ្លួន។

ទម្រង់ និងព័ត៌មាននៃលិខិតបញ្ជាក់ភាពនៅលើវ ឬមេម៉ាយ ឬពោះម៉ាយ ជាឧបសម្ព័ន្ធទី១៩ នៃប្រកាសនេះ។

ផ្នែកទី៩
ការទទួលស្គាល់អាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរនៅបរទេស

ប្រការ៦៤.- នីតិវិធីនៃការទទួលស្គាល់អាពាហ៍ពិពាហ៍នៃប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋខ្មែរនៅបរទេស

អាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋខ្មែរ ដែលត្រូវបានធ្វើឡើងស្របច្បាប់បរទេសដែលអនុវត្តនៅទីកន្លែងអាពាហ៍ពិពាហ៍បានធ្វើឡើង ត្រូវទទួលស្គាល់ឱ្យចុះបញ្ជីអាពាហ៍ពិពាហ៍នៅព្រះរាជាណាចក្រកម្ពុជាបាន ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយពីបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

សាមីខ្លួន អាចចុះបញ្ជីអាពាហ៍ពិពាហ៍នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ប្តីប្រពន្ធ ឬចុះបញ្ជីអាពាហ៍ពិពាហ៍នៅរដ្ឋបាលឃុំ សង្កាត់ ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ប្តីប្រពន្ធនោះ ដោយត្រូវភ្ជាប់មកជាមួយនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចេញដោយអាជ្ញាធរ បរទេសមានសមត្ថកិច្ច សំបុត្រអាពាហ៍ពិពាហ៍ដែលបានបកប្រែជាភាសាខ្មែរ ឯកសារអត្តសញ្ញាណរបស់សាមីខ្លួន និងឯកសារបញ្ជាក់អំពីការស្នាក់នៅ។

ទម្រង់ និងព័ត៌មាននៃពាក្យសុំទទួលស្គាល់អាពាហ៍ពិពាហ៍ប្រជាពលរដ្ឋខ្មែរនៅបរទេស ជាក្រដាស និង/ឬអេឡិចត្រូនិក ជាឧបសម្ព័ន្ធទី២០ នៃប្រកាសនេះ។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់។ ក្រោយពីបានពិនិត្យឃើញត្រឹមត្រូវហើយ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍ស្របតាមបែបបទ និងនីតិវិធីដែលមានកំណត់ក្នុងប្រការ៤៩ នៃប្រកាសនេះ ដោយមិនតម្រូវឱ្យមានសាក្សីចំនួនពីរូប ជានីតិជននោះទេ។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវសម្រេចចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ដោយកំណត់យកថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ និងទីកន្លែងចុះអាពាហ៍ពិពាហ៍ឱ្យដូចសំបុត្រអាពាហ៍ពិពាហ៍នៅបរទេស និងត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចំនួន ១(ច្បាប់) ដោយចុះកាលបរិច្ឆេទថ្មីទៅតាមពេលវេលាជាក់ស្តែង។

ជំពូកទី៧
ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន

ផ្នែកទី១
បុគ្គលដែលអាចស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន

ប្រការ៦៥.- បុគ្គលស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន

បុគ្គលដែលអាចស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សាមីខ្លួនជានីតិជននៃសំបុត្រកំណើត និងសាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍។

ខ- ឪពុក ឬម្តាយ ឬអាណាព្យាបាល។

គ- សហព័ទ្ធ។

ឃ- ញាតិដែលមានឈ្មោះនៅក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬឯកសារបញ្ជាក់អំពីទំនាក់ទំនងញាតិ។

ង- អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិរបស់បុគ្គលខាងលើ ដូចមានចែងក្នុងចំណុច "ក" "ខ" និង "គ"។

ផ្នែកទី២
ទម្រង់ បែបបទ និងការដាក់ពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន

ប្រការ៦៦.- ទម្រង់ និងព័ត៌មានពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន

ព័ត៌មាននៅក្នុងពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់សាមីខ្លួននៃបញ្ជីអត្រានុកូលដ្ឋាន
- សញ្ជាតិរបស់សាមីខ្លួននៃបញ្ជីអត្រានុកូលដ្ឋាន
- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់សាមីខ្លួននៃបញ្ជីអត្រានុកូលដ្ឋាន (ប្រសិនបើមាន)
- ព័ត៌មានបញ្ជីអត្រានុកូលដ្ឋាន
- ទីកន្លែងចុះបញ្ជី
- នាមត្រកូល និងនាមខ្លួនរបស់អ្នកស្នើសុំ
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកស្នើសុំ
- លំនៅឋានបច្ចុប្បន្នរបស់អ្នកស្នើសុំ។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន ជាក្រដាស និង/ឬអេឡិចត្រូនិក ជាឧបសម្ព័ន្ធទី២១ នៃប្រកាសនេះ។

ករណីពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋានក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្ទង់ទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៦៧.- ទីកន្លែង និងការដាក់ពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន

ទីកន្លែង និងការដាក់ពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋានត្រូវបានកំណត់ដូចខាងក្រោម៖

ក- ចំពោះបុគ្គលដែលបានប្រើប្រាស់សំបុត្រអត្រានុកូលដ្ឋានគំរូថ្មី ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ អាចដាក់ពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន នៅ៖

- រដ្ឋបាលឃុំ សង្កាត់ នៃទីកន្លែងចុះបញ្ជីអត្រានុកូលដ្ឋាន ឬ
- ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស នៃទីកន្លែងចុះបញ្ជីអត្រានុកូលដ្ឋាន ឬ
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីកន្លែងចុះបញ្ជីអត្រានុកូលដ្ឋាន ឬ
- រដ្ឋបាលរាជធានី ខេត្ត នៃទីកន្លែងចុះបញ្ជីអត្រានុកូលដ្ឋាន ឬ
- នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

ខ- ចំពោះបុគ្គលដែលបានប្រើប្រាស់សំបុត្រអត្រានុកូលដ្ឋានគំរូចាស់ ស្របតាមអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន អាចដាក់ពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន នៅ៖

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីកន្លែងរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន ឬ
- នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

គ- កន្លែងផ្សេងទៀត តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

ការដាក់ពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។

ការស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃចំនួន ២(ពីរ)ច្បាប់ ដោយ ១(មួយ)ច្បាប់ ជូនអ្នកដាក់ពាក្យសុំ និង ១(មួយ)ច្បាប់ទៀតត្រូវរក្សាទុកនៅទីកន្លែងស្នើសុំ។

ផ្នែកទី៣
ឯកសារភ្ជាប់សម្រាប់ស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន

ប្រការ៦៨.- ឯកសារភ្ជាប់

ឯកសារភ្ជាប់សម្រាប់សុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋានត្រូវបានកំណត់ដូចខាងក្រោម៖

ក- សំបុត្រអត្រានុកូលដ្ឋាន ឬសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និង/ឬ

ខ- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល ឬ
គ- បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត
ឃ- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ករណីអ្នកស្នើសុំមិនមែនជាសាមីខ្លួន ឬឪពុកម្តាយ ឬ
ង- ឯកសារបញ្ជាក់អំពីទំនាក់ទំនងញាតិ ឬសហព័ទ្ធរបស់សាមីខ្លួន ឬ
ច- ឯកសារបញ្ជាក់អំពីអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិ។

ផ្នែកទី៤
នីតិវិធីនៃការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន

ប្រការ៦៩.- ដំណើរការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន នៅរដ្ឋបាលឃុំ សង្កាត់ និងនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

នីតិវិធីនៃការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាននៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន និងឯកសារភ្ជាប់ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាណាចក្រកម្ពុជានៅបរទេស ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់។

២. ករណីព័ត៌មាននៃពាក្យសុំ និងឯកសារភ្ជាប់គ្រប់គ្រាន់និងត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យនៅរដ្ឋបាល ឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវស្វែងរកទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

៣. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានជាមួយសំបុត្រអត្រានុកូលដ្ឋាន ក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ បើពិនិត្យឃើញថាត្រឹមត្រូវ ត្រូវបោះពុម្ពសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋានចេញពីប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា។

៤. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវពិនិត្យសម្រេចចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន មិនឱ្យលើសរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

៥. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវស្នែនពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន និងឯកសារភ្ជាប់ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាឯកសារទាំងនោះនៅទីកន្លែងស្នើសុំ។



៦. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវប្រគល់សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន ជូនអ្នកស្នើសុំ។

ប្រការ៧០.- ដំណើរការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

នីតិវិធីនៃការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន និងឯកសារភ្ជាប់ មន្ត្រីទទួលពាក្យ ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់។

២. ករណីព័ត៌មាននៃពាក្យសុំ និងឯកសារភ្ជាប់ គ្រប់គ្រាន់ និងត្រឹមត្រូវហើយ មន្ត្រីទទួលបន្ទុកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវស្វែងរកទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ដូចខាងក្រោម៖

- ករណីមានទិន្នន័យនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីទទួលបន្ទុក ត្រូវបោះពុម្ពសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់ក្រុង ស្រុក ខណ្ឌ
- ករណីមិនមានទិន្នន័យនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីទទួលបន្ទុកត្រូវវាយបញ្ចូលទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវលើកយោបល់ស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល រួចបោះពុម្ពសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវ ស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល និងពិនិត្យសម្រេចចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន មិនឱ្យលើសរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

៤. មន្ត្រីទទួលបន្ទុក ត្រូវស្កែនពាក្យសុំ និងឯកសារភ្ជាប់ ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកឯកសារទាំងនោះនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៥. មន្ត្រីទទួលពាក្យ ត្រូវប្រគល់សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន ជូនអ្នកស្នើសុំ។

ប្រការ៧១.- ដំណើរការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន នៅរដ្ឋបាលរាជធានី ខេត្ត

នីតិវិធីនៃការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាននៅរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តដូចខាងក្រោម៖



១. បន្ទាប់ពីទទួលបានពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន និងឯកសារភ្ជាប់ មន្ត្រីទទួលពាក្យ ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់។

២. ករណីព័ត៌មាននៃពាក្យសុំ និងឯកសារភ្ជាប់គ្រប់គ្រាន់និងត្រឹមត្រូវហើយ មន្ត្រីទទួលបន្ទុកនៅរដ្ឋបាល រាជធានី ខេត្ត ត្រូវស្វែងរកទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

៣. មន្ត្រីទទួលបន្ទុកត្រូវពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានជាមួយសំបុត្រអត្រានុកូលដ្ឋាន ក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ បើពិនិត្យឃើញថាត្រឹមត្រូវ ត្រូវបោះពុម្ពសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត។

៤. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យសម្រេចចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន មិនឱ្យលើសរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

៥. មន្ត្រីទទួលបន្ទុកត្រូវស្នែនពាក្យសុំ និងឯកសារភ្ជាប់ ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកឯកសារទាំងនោះនៅរដ្ឋបាលរាជធានី ខេត្ត។

៦. មន្ត្រីទទួលពាក្យ ត្រូវប្រគល់សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន ជូនអ្នកស្នើសុំ។

ប្រការ៧២.- ដំណើរការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ

នីតិវិធីនៃការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាននៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវអនុវត្តដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន និងឯកសារភ្ជាប់ មន្ត្រីទទួលពាក្យនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់។

២. ករណីព័ត៌មាននៃពាក្យសុំ និងឯកសារភ្ជាប់គ្រប់គ្រាន់និងត្រឹមត្រូវហើយ មន្ត្រីទទួលបន្ទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវស្វែងរកទិន្នន័យ នៃបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ដូចខាងក្រោម៖

- ករណីមានទិន្នន័យនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីទទួលបន្ទុកត្រូវបោះពុម្ពសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ
- ករណីមិនមានទិន្នន័យនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីទទួលបន្ទុកត្រូវបំពេញបញ្ចូលទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវលើកយោបល់ស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល រួចបោះពុម្ពសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល និងពិនិត្យសម្រេចចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់បញ្ជីអត្រានុកូលដ្ឋាន មិនឱ្យលើសរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។



៤. មន្ត្រីទទួលបន្ទុក ត្រូវស្នែនពាក្យសុំ និងឯកសារភ្ជាប់ ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកឯកសារទាំងនោះនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

៥. មន្ត្រីទទួលពាក្យត្រូវប្រគល់សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋាន ជូនអ្នកស្នើសុំ។

ជំពូកទី៨
ការកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ

ផ្នែកទី១
ទម្រង់ បែបបទ និងការដាក់ពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ

ប្រការ៧៣.- ទម្រង់ និងព័ត៌មានពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ

ព័ត៌មាននៅក្នុងពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គល ដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់សាមីខ្លួន
- ភេទរបស់សាមីខ្លួន
- សញ្ជាតិរបស់សាមីខ្លួន
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់សាមីខ្លួន
- ទីកន្លែងកំណើតរបស់សាមីខ្លួន
- លំនៅឋានបច្ចុប្បន្នរបស់សាមីខ្លួន។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គល ដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី២២** នៃប្រកាសនេះ។

ករណីពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គល ដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្ទង់ទិន្នន័យ សម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៧៤.- ការដាក់ពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ

សាមីខ្លួន ឬឪពុកឬម្តាយ អាចដាក់ពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ នៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

ការដាក់ពាក្យសុំ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។

មន្ត្រីទទួលពាក្យសុំនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវចេញបង្កាន់ដៃចំនួន ១(មួយ)ច្បាប់ ជូនអ្នកស្នើសុំ។

ផ្នែកទី២
ឯកសារភ្ជាប់សម្រាប់កត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបាន ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ

ប្រការ៧៥.- ឯកសារភ្ជាប់សម្រាប់កត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបាន ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ

ឯកសារភ្ជាប់សម្រាប់តក់ត្រាព័ត៌មានកំណើតរស់របស់បុគ្គល ដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ត្រូវបានកំណត់ដូចខាងក្រោម៖

- ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ដែលបានធ្វើនីត្យានុកូលកម្ម និង
- សំបុត្រកំណើតដែលចេញដោយប្រទេសសាមី និង
- លិខិតឆ្លងដែន និង/ឬ
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត និង
- សៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និង/ឬ
- ឯកសារភស្តុតាងផ្សេងទៀតរបស់សាមីខ្លួន និង/ឬឪពុក ម្តាយ។

ផ្នែកទី៣
នីតិវិធីនៃការកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបាន ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ

ប្រការ៧៦.- ដំណើរការកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ

ការកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គលដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គល ដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ និងឯកសារភ្ជាប់ មន្ត្រីទទួលពាក្យនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់។

២. ករណីព័ត៌មានពាក្យសុំកត់ត្រាព័ត៌មានកំណើតរស់របស់បុគ្គល ដែលទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ និងឯកសារភ្ជាប់គ្រប់គ្រាន់និងត្រឹមត្រូវហើយ មន្ត្រីទទួលបន្ទុក ត្រូវកត់ត្រាព័ត៌មានពីពាក្យសុំទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

៣. មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានជាមួយពាក្យសុំ និងឯកសារភ្ជាប់។ បើពិនិត្យឃើញថាត្រឹមត្រូវ មន្ត្រីទទួលបន្ទុក ត្រូវលើកយោបល់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល។

៤. មន្ត្រីទទួលបន្ទុក ត្រូវបោះពុម្ពបញ្ជីកំណើតរស់ចំនួន ១(មួយ)ច្បាប់ ដើម្បីឱ្យអ្នកស្នើសុំផ្តិតស្នាមម្រាមដៃ និងសេចក្តីចម្លងសំបុត្រកំណើតតាមការស្នើសុំ មុននឹងដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៥. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវពិនិត្យសម្រេចលើបញ្ជីកំណើតរស់ និងស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន មិនឱ្យលើសរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

៦. មន្ត្រីទទួលបន្ទុក ត្រូវស្កែនពាក្យសុំបញ្ជីកំណើតរស់ សេចក្តីចម្លងសំបុត្រកំណើត និងឯកសារភ្ជាប់ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកពាក្យសុំ បញ្ជីកំណើតរស់ និងឯកសារភ្ជាប់នៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ។

៧. មន្ត្រីទទួលពាក្យ ត្រូវប្រគល់សេចក្តីចម្លងសំបុត្រកំណើត ជូនអ្នកស្នើសុំ។

ជំពូកទី៩
ការផ្តល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់
ផ្នែកទី១
បុគ្គលដែលអាចស្នើសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញ ករណីខូចខាត ឬបាត់បង់

ប្រការ៧៧.- បុគ្គលដែលអាចស្នើសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញ ករណីខូចខាត ឬបាត់បង់

បុគ្គលដែលអាចស្នើសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់ មានដូចខាងក្រោម៖

ក- សាមីខ្លួនជានីតិជននៃសំបុត្រកំណើត និងសាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍។

ខ- ឪពុក ឬម្តាយ ឬអាណាព្យាបាល។

គ- សហព័ទ្ធ។

ឃ- ញាតិជានីតិជនដែលមានឈ្មោះនៅក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬឯកសារបញ្ជាក់អំពីទំនាក់ទំនងញាតិ។

ផ្នែកទី២
ទម្រង់ បែបបទ និងការដាក់ពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញ ករណីខូចខាត ឬបាត់បង់

ប្រការ៧៨.- ទម្រង់ និងព័ត៌មានពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញ ករណីខូចខាត ឬបាត់បង់

ព័ត៌មានចាំបាច់នៅក្នុងពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់ មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់សាមីខ្លួននៃសំបុត្រអត្រានុកូលដ្ឋាន
- សញ្ជាតិរបស់សាមីខ្លួននៃសំបុត្រអត្រានុកូលដ្ឋាន

- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់សាមីខ្លួននៃសំបុត្រអត្រានុកូលដ្ឋាន (ប្រសិនបើមាន)
- ព័ត៌មានបញ្ជីអត្រានុកូលដ្ឋាន
- ទីកន្លែងចុះបញ្ជីអត្រានុកូលដ្ឋាន
- នាមត្រកូល និងនាមខ្លួនរបស់អ្នកស្នើសុំ
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកស្នើសុំ
- លំនៅឋានបច្ចុប្បន្នរបស់អ្នកស្នើសុំ។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់ ជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី២៣** នៃប្រកាសនេះ។

ករណីពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញ ករណីខូចខាត ឬបាត់បង់ ក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្ទង់ទិន្នន័យ សម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៧៩.- ទីកន្លែង និងការដាក់ពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់

ក្នុងករណីសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមខូចខាត ឬបាត់បង់ អ្នកស្នើសុំអាចដាក់ពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីកន្លែងរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន ឬនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

ការដាក់ពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។

មន្ត្រីទទួលពាក្យនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវចេញបង្កាន់ដៃចំនួន ១(មួយ)ច្បាប់ ជូនអ្នកស្នើសុំ។

ផ្នែកទី៣
ឯកសារភ្ជាប់សម្រាប់ស្នើសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់

ប្រការ៨០.- ឯកសារភ្ជាប់សម្រាប់ស្នើសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់

ឯកសារភ្ជាប់សម្រាប់ស្នើសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់ ត្រូវបានកំណត់ដូចខាងក្រោម៖

- សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមដែលខូចខាត ឬពាក្យបណ្តឹងអំពីការបាត់បង់សំបុត្រអត្រានុកូលដ្ឋាន
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល ឬបណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់។

ផ្នែកទី៤
នីតិវិធីនៃការផ្តល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់

ប្រការ៨១.- ដំណើរការផ្តល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់

ការផ្តល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលបានពាក្យសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមឡើងវិញករណីខូចខាត ឬបាត់បង់ និងឯកសារភ្ជាប់ មន្ត្រីទទួលពាក្យនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវ នៃពាក្យសុំ និងឯកសារភ្ជាប់។

២. ករណីព័ត៌មាននៃពាក្យសុំ និងឯកសារភ្ជាប់ គ្រប់គ្រាន់ និងត្រឹមត្រូវហើយ មន្ត្រីទទួលបន្ទុកនៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវស្វែងរកទិន្នន័យ នៃបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ដូចខាងក្រោម៖

ក- ករណីមានទិន្នន័យនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីទទួលបន្ទុក ត្រូវបោះពុម្ពសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមថ្មី ចំនួន ១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

ខ- ករណីមិនមានទិន្នន័យនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីទទួលបន្ទុកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវរៀបចំបញ្ចូលទិន្នន័យ និងស្នែនបញ្ជីនោះទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ មន្ត្រីទទួលបន្ទុកត្រូវលើកយោបល់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីស្នើសុំលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ហើយត្រូវបោះពុម្ពសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ចំនួន ១(មួយ)ច្បាប់ ជាក់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវពិនិត្យសម្រេចចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ដោយចុះកាលបរិច្ឆេទថ្មីទៅតាមពេលវេលាជាក់ស្តែង មិនឱ្យលើសរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

៤. មន្ត្រីទទួលបន្ទុក ត្រូវស្នែនពាក្យសុំ សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងឯកសារភ្ជាប់ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងត្រូវរក្សាទុកពាក្យសុំ និងឯកសារភ្ជាប់នៅទីកន្លែងស្នើសុំ។



៥. មន្ត្រីទទួលពាក្យ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវប្រគល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ជូនអ្នកស្នើសុំ។

ជំពូកទី១០
ការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ផ្នែកទី១
ប្រភេទនៃការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ប្រការ៨២.- ប្រភេទនៃការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្តរួមមាន ការចុះបញ្ជីក្នុងករណីឪពុកទទួលស្គាល់កូនជាអនីតិជន ការចុះបញ្ជីក្នុងករណីឪពុកទទួលស្គាល់កូនជានីតិជន ការចុះបញ្ជីក្នុងករណីឪពុកទទួលស្គាល់ទារកនៅក្នុងគភ៌ ការចុះបញ្ជីក្នុងករណីឪពុកទទួលស្គាល់កូនដែលបានទទួលមរណភាព និងការចុះបញ្ជីក្នុងករណីឪពុកទទួលស្គាល់កូនតាមមតកសាសន៍។

ផ្នែកទី២
ទម្រង់ បែបបទ និងការដាក់ពាក្យសុំចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ប្រការ៨៣.- ទម្រង់ និងព័ត៌មានពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្ត

ព័ត៌មាននៅក្នុងពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្ត មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់អ្នកកើត
- សញ្ជាតិរបស់អ្នកកើត
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកកើត
- ទីកន្លែងកំណើតរបស់អ្នកកើត
- ព័ត៌មានបញ្ជីអត្រានុកូលដ្ឋានរបស់អ្នកកើត
- ទីកន្លែងចុះបញ្ជី
- នាមត្រកូល និងនាមខ្លួនរបស់ឪពុកម្តាយ
- សញ្ជាតិរបស់ឪពុកម្តាយ
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុកម្តាយ
- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់ឪពុកម្តាយ។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្តជាក្រដាស និង/ឬ អេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី២៤** នៃប្រកាសនេះ។

ករណីពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្តក្នុងទម្រង់ជាអេឡិចត្រូនិក អាចមានបន្ថែមខ្លឹមសារទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៨៤.- ទីកន្លែង និងការដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្ត

ការដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្ត ត្រូវបានកំណត់ដូចខាងក្រោម៖

១. ក្នុងករណីការចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្តក្នុងឆ្នាំអនុវត្ត ឪពុក ឬអ្នកប្រតិបត្តិមតកសាសន៍ អាចដាក់ពាក្យសុំនៅទីកន្លែងនៃរដ្ឋបាលឃុំ សង្កាត់ ឬនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ដែលបានចុះបញ្ជីកំណើតរស់របស់កូននោះ។

២. ក្នុងករណីការចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្តហួសឆ្នាំអនុវត្ត ឪពុក ឬអ្នកប្រតិបត្តិមតកសាសន៍ អាចដាក់ពាក្យសុំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីកន្លែងរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន ឬនាយកដ្ឋានអត្រានុ-កូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

៣. ការដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្ត ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។

៤. មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ឬនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវចេញបង្កាន់ដៃចំនួន ១(មួយ)ច្បាប់ ជូនអ្នកស្នើសុំ។

ប្រការ៨៥.- ទម្រង់ និងព័ត៌មាននៃលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត

ព័ត៌មាននៃលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់ឪពុកម្តាយ
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុកម្តាយ
- លំនៅឋានបច្ចុប្បន្នរបស់ឪពុកម្តាយ
- នាមត្រកូល និងនាមខ្លួនរបស់កូន
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់កូន
- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់កូន។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ជា**ឧបសម្ព័ន្ធទី២៥** នៃប្រកាសនេះ។

ផ្នែកទី៣
ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ប្រការ៨៦.- ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត ត្រូវបានកំណត់ដូចខាងក្រោម៖

- សំបុត្រកំណើតច្បាប់ដើមរបស់កូន ឬពាក្យបណ្តឹងអំពីការបាត់បង់សំបុត្រកំណើតច្បាប់ដើម
- លិខិតមតកសាសន៍ (ក្នុងករណីការទទួលស្គាល់កូនតាមមតកសាសន៍)
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬបណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល
- លិខិតវេជ្ជសាស្ត្របញ្ជាក់អំពីទារកក្នុងគភ៌ (លិខិតពិនិត្យផ្ទៃពោះរបស់ម្តាយ)
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់។

ផ្នែកទី៤

នីតិវិធីនៃការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្តនៅរដ្ឋបាលឃុំ សង្កាត់ និងនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

ប្រការ៨៧.- ដំណើរការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្តនៅរដ្ឋបាលឃុំ សង្កាត់ និងនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្ត និងឯកសារភ្ជាប់ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់។

២. ករណីព័ត៌មាននៃពាក្យសុំ និងឯកសារភ្ជាប់គ្រប់គ្រាន់ និងត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យ និងមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវអនុវត្តដូចខាងក្រោម៖

ក- ក្នុងករណីឪពុកទទួលស្គាល់កូនដោយស្ម័គ្រចិត្ត មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវកត់ត្រាព័ត៌មានពាក្យសុំចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រួចត្រូវបោះពុម្ពលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ចំនួន ១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវសម្រេចចេញលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ដោយមានការយល់ព្រមពីម្តាយ ឬអ្នកអាណាព្យាបាលករណីកូនជាអនីតិជន ឬត្រូវមានការយល់ព្រមពីសាមីខ្លួនករណីកូនជានីតិជន។ ការយល់ព្រមនេះ ត្រូវផ្តិតស្នាមម្រាមដៃ នៅលើលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ខ- ក្នុងករណីឪពុកទទួលស្គាល់ទារកនៅក្នុងគភ៌ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវកត់ត្រាព័ត៌មានពាក្យសុំចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រួចត្រូវបោះពុម្ពលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ចំនួន ១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។ បន្ទាប់មក មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាត្រូវសម្រេចចេញលិខិតទទួលស្គាល់ទារកនៅក្នុងគភ៌ដោយស្ម័គ្រចិត្ត លុះត្រាតែម្តាយរបស់ទារកក្នុងគភ៌យល់ព្រម ដោយត្រូវផ្តិតស្នាមម្រាមដៃនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

គ- ក្នុងករណីឪពុកទទួលស្គាល់កូនដែលបានទទួលមរណភាព មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវកត់ត្រាព័ត៌មានពាក្យសុំចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រួចត្រូវបោះពុម្ពលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ចំនួន ១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។ បន្ទាប់មក មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវសម្រេចចេញលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត បានលុះត្រាតែកូននោះមានបច្ឆាជាតិផ្សេងតែប៉ុណ្ណោះ។ ករណីកូននោះមានបច្ឆាជាតិជាអនីតិជន ឪពុកដែលស្នើសុំនោះត្រូវផ្តិតស្នាម

ម្រាមដៃលើលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្តតែម្នាក់ឯង និងករណីកូននោះមានបច្ចាញ្ជាតិជានីតិជន ឪពុកដែលស្នើសុំត្រូវមានការយល់ព្រមពីបច្ចាញ្ជាតិជានីតិជនដោយត្រូវផ្តិតស្នាមម្រាមដៃលើលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ឃ- ក្នុងករណីឪពុកទទួលស្គាល់កូនតាមមតកសាសន៍ មន្ត្រីទទួលពាក្យនៅរដ្ឋបាលឃុំ សង្កាត់ ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវកត់ត្រាព័ត៌មានពាក្យសុំចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រួចត្រូវបោះពុម្ពលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ចំនួន ១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។ បន្ទាប់មក មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាត្រូវសម្រេចចេញលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ដោយត្រូវមានការយល់ព្រមពីម្តាយ ឬអ្នកអាណាព្យាបាលករណីកូនជាអនីតិជន ឬត្រូវមានការយល់ព្រមពីសាមីខ្លួនករណីកូនជានីតិជន។ ការយល់ព្រមនេះ ត្រូវផ្តិតស្នាមម្រាមដៃលើលិខិតទទួលស្គាល់ ដោយស្ម័គ្រចិត្តនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

៣. ក្នុងករណីឪពុកទទួលស្គាល់កូនដោយស្ម័គ្រចិត្ត មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកែតម្រូវបញ្ជីកំណើតរស់ និងចេញសំបុត្រកំណើតច្បាប់ដើមថ្មី ដោយអនុវត្តស្របតាមនីតិវិធីនៃការកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែក្នុងករណីដែលឪពុកទទួលស្គាល់ទារកនៅក្នុងគភ៌។

ផ្នែកទី៥
នីតិវិធីនៃការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ

ប្រការ៨៨.- ដំណើរការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលពាក្យសុំចុះបញ្ជីទទួលស្គាល់ដោយស្ម័គ្រចិត្ត និងឯកសារភ្ជាប់ មន្ត្រីទទួលពាក្យនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំ និងឯកសារភ្ជាប់។

២. ករណីព័ត៌មាននៃពាក្យសុំ និងឯកសារភ្ជាប់ គ្រប់គ្រាន់ និងត្រឹមត្រូវហើយ មន្ត្រីទទួលបន្ទុក និងមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវអនុវត្តដូចខាងក្រោម៖

ក- ក្នុងករណីឪពុកទទួលស្គាល់កូនដោយស្ម័គ្រចិត្ត មន្ត្រីទទួលបន្ទុកត្រូវកត់ត្រាព័ត៌មានពាក្យសុំចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រួចត្រូវបោះពុម្ពលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ចំនួន ១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចចេញលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ដោយមានការយល់ព្រមពីម្តាយ ឬអ្នកអាណាព្យាបាលករណីកូនជាអនីតិជន ឬត្រូវមានការយល់ព្រមពីសាមីខ្លួនករណីកូនជានីតិជន។ ការយល់ព្រមនេះ ត្រូវផ្តិតស្នាមម្រាមដៃលើលិខិតទទួលស្គាល់ដោយស្ម័គ្រចិត្ត ។

ខ- ក្នុងករណីឪពុកទទួលស្គាល់ទារកនៅក្នុងគភ៌ មន្ត្រីទទួលបន្ទុកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវកត់ត្រាព័ត៌មានពាក្យសុំចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រួចត្រូវបោះពុម្ពលិខិតទទួលស្គាល់ដោយស្មគ្រចិត្ត ចំនួន ១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។ បន្ទាប់មក មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចចេញលិខិតទទួលស្គាល់ទារកនៅក្នុងគភ៌ដោយស្មគ្រចិត្ត លុះត្រាតែម្តាយរបស់ទារកក្នុងគភ៌យល់ព្រមដោយត្រូវផ្តិតស្នាមម្រាមដៃ។

គ- ក្នុងករណីឪពុកទទួលស្គាល់កូនដែលបានទទួលមរណភាព មន្ត្រីទទួលបន្ទុកត្រូវកត់ត្រាព័ត៌មានពាក្យសុំចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រួចត្រូវបោះពុម្ពលិខិតទទួលស្គាល់ដោយស្មគ្រចិត្ត ចំនួន១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។ បន្ទាប់មក មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចចេញលិខិតទទួលស្គាល់ដោយស្មគ្រចិត្ត លុះត្រាតែកូននោះមានបច្ចាញ្ជាតិផ្ទាល់តែប៉ុណ្ណោះ។ ករណីកូននោះមានបច្ចាញ្ជាតិជាអនីតិជន ឪពុកដែលស្នើសុំនោះត្រូវផ្តិតស្នាមម្រាមដៃលើលិខិតទទួលស្គាល់ដោយស្មគ្រចិត្តតែម្នាក់ឯង និងករណីកូននោះមានបច្ចាញ្ជាតិជានីតិជន ឪពុកដែលស្នើសុំត្រូវមានការយល់ព្រមពីបច្ចាញ្ជាតិជានីតិជន ដោយត្រូវផ្តិតស្នាមម្រាមដៃលើលិខិតទទួលស្គាល់ដោយស្មគ្រចិត្ត។

ឃ- ក្នុងករណីឪពុកទទួលស្គាល់កូនតាមមតកសាសន៍ មន្ត្រីទទួលបន្ទុកត្រូវកត់ត្រាព័ត៌មានពាក្យសុំចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រួចត្រូវបោះពុម្ពលិខិតទទួលស្គាល់ដោយស្មគ្រចិត្ត ចំនួន ១(មួយ)ច្បាប់ ដើម្បីដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចចេញលិខិតទទួលស្គាល់ដោយស្មគ្រចិត្ត ដោយត្រូវមានការយល់ព្រមពីម្តាយ ឬអ្នកអាណាព្យាបាលករណីកូនជាអនីតិជន ឬត្រូវមានការយល់ព្រមពីសាមីខ្លួនករណីកូនជានីតិជន។ ការយល់ព្រមនេះ ត្រូវផ្តិតស្នាមម្រាមដៃលើលិខិតទទួលស្គាល់ដោយស្មគ្រចិត្ត។

៣. ក្នុងករណីឪពុកទទួលស្គាល់កូនដោយស្មគ្រចិត្ត មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ឬមន្ត្រីអត្រានុកូលដ្ឋានក្រុង ស្រុក ខណ្ឌ ត្រូវតែកែតម្រូវបញ្ជីកំណើតរស់ និងចេញសំបុត្រកំណើតច្បាប់ដើមថ្មី ដោយអនុវត្តស្របតាមនីតិវិធីនៃការកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែក្នុងករណីដែលឪពុកទទួលស្គាល់ទារកនៅក្នុងគភ៌។

ជំពូកទី១១
ការគ្រប់គ្រង និងការបោះពុម្ពក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ

ប្រការ៨៩.- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានការកិច្ចក្នុងការគ្រប់គ្រង ផ្គត់ផ្គង់ និងបោះពុម្ពក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ។

នាយកដ្ឋានអត្រានុកូលដ្ឋាន ជាសេនាធិការជូនអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានការកិច្ចរៀបចំផែនការបោះពុម្ពក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ។

នាយកដ្ឋានអត្រានុកូលដ្ឋាន ត្រូវរក្សាទុកក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដែលបានបោះពុម្ពរួចឱ្យបានត្រឹមត្រូវ ដើម្បីធានាការផ្គត់ផ្គង់ និងបែងចែកក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទដល់រដ្ឋបាលរាជធានី ខេត្ត និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស សម្រាប់ប្រើប្រាស់។

ប្រការ៩០.- រដ្ឋបាលរាជធានី ខេត្ត

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការប្រើប្រាស់ក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដើម្បីស្នើសុំមកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងត្រូវធានាការផ្គត់ផ្គង់ក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ប្រើប្រាស់។

ប្រការ៩១.- រដ្ឋបាលក្រុង ស្រុក ខណ្ឌ

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការប្រើប្រាស់ក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដើម្បីស្នើសុំមករដ្ឋបាលរាជធានី ខេត្ត និងត្រូវធានាការផ្គត់ផ្គង់ក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទដល់រដ្ឋបាល ឃុំ សង្កាត់ សម្រាប់ប្រើប្រាស់។

ប្រការ៩២.- រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំផែនការប្រើប្រាស់ក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដើម្បីស្នើសុំមករដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវធានាការចុះបញ្ជីអត្រានុកូលដ្ឋានជូនដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ប្រការ៩៣.- ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា

ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំផែនការប្រើប្រាស់ក្រដាសសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដើម្បីស្នើសុំមកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងត្រូវធានាការចុះបញ្ជីអត្រានុកូលដ្ឋានជូនដល់ប្រជាពលរដ្ឋខ្មែរក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជំពូកទី១២
ការធ្វើបច្ចុប្បន្នភាពបញ្ជីអត្រានុកូលដ្ឋាន ការថែទាំ ការរក្សាទុក ការបញ្ជូនបញ្ជីព័ត៌មាន និងរបាយការណ៍ស្តីពីការចារអត្រានុកូលដ្ឋាន
ផ្នែកទី១
ការធ្វើបច្ចុប្បន្នភាពបញ្ជីអត្រានុកូលដ្ឋាន

ប្រការ៩៤.- នីតិវិធីនៃការធ្វើបច្ចុប្បន្នភាពបញ្ជីអត្រានុកូលដ្ឋាន

ករណីបញ្ជីអត្រានុកូលដ្ឋានណាមួយមានការប្រែប្រួលព័ត៌មាន មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវធានាថា បញ្ជីអត្រានុកូលដ្ឋានផ្សេងទៀត ត្រូវបានធ្វើបច្ចុប្បន្នភាព ដូចខាងក្រោម៖

១. ករណីមានការចុះបញ្ជីមរណភាព បញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតរបស់មរណជនត្រូវចុះនិទ្ទេសថា "ស្លាប់" ដោយស្វ័យប្រវត្តិនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ រាល់ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងសម្រង់បញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតរបស់មរណជន ដែលចេញក្រោយពេលចុះបញ្ជីមរណភាពត្រូវចុះនិទ្ទេសថា "ស្លាប់"។

២. ករណីបុគ្គលដែលត្រូវបានចុះបញ្ជីមរណភាពអនុលោមតាមមាត្រា៦១ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ការចុះបញ្ជីបុគ្គលដែលត្រូវបានចាត់ទុកថាបានទទួលមរណភាព) ដែលត្រូវបានតុលាការកំណត់នៅពេលក្រោយថា "នៅរស់" បញ្ជីមរណភាពរបស់មរណជននោះត្រូវចុះនិទ្ទេសថា "មោឃភាព"។ បញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតរបស់បុគ្គល ដែលបានចុះនិទ្ទេសពីមុនមកថា "ស្លាប់" ត្រូវចុះនិទ្ទេស ថា "នៅរស់"វិញ។

៣. ករណីការចុះបញ្ជីអំពីការលែងលះ មោឃភាព និងលុបចោលអាពាហ៍ពិពាហ៍តាមសេចក្តីសម្រេចរបស់តុលាការ បញ្ជីអាពាហ៍ពិពាហ៍របស់បុគ្គលនោះ ត្រូវចុះនិទ្ទេសថា "លែងលះ" ឬ "មោឃភាព" ឬ "លុបចោល"។

៤. ករណីបញ្ជីកំណើតរស់ របស់បុគ្គលណាម្នាក់បានកែតម្រូវទិន្នន័យរួចរាល់ បញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតរបស់បុគ្គលនោះក៏ត្រូវធ្វើបច្ចុប្បន្នភាពដោយស្វ័យប្រវត្តិផងដែរ។

ផ្នែកទី២
នីតិវិធីនៃការថែទាំ និងរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន

ប្រការ៤៥.- ការថែទាំ និងការរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន

ការថែទាំ និងរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បញ្ជីអត្រានុកូលដ្ឋាន រួមមានបញ្ជីកំណើតរស់ បញ្ជីមរណភាព និងបញ្ជីអាពាហ៍ពិពាហ៍ក្នុងទម្រង់ជាអេឡិចត្រូនិក ត្រូវថែទាំនិងរក្សាទុកជាអចិន្ត្រៃយ៍។

២. ពាក្យសុំ និងឯកសារភ្ជាប់ ត្រូវថែទាំនិងរក្សាទុក ក្នុងទម្រង់ជាអេឡិចត្រូនិកនៅក្នុងរយៈពេល ៧០ (ចិតសិប)ឆ្នាំ និងអាចលុបចោលដោយស្វ័យប្រវត្តិក្រោយផុតរយៈពេលកំណត់នេះ។ ចំពោះពាក្យសុំ និងឯកសារភ្ជាប់ក្នុងទម្រង់ជាក្រដាស ត្រូវថែទាំ និងរក្សាទុកនៅរដ្ឋបាលឃុំ សង្កាត់ យ៉ាងតិចរយៈពេល ១៥(ដប់ប្រាំ)ឆ្នាំ និងអាចបំផ្លាញចោលបានក្រោយផុតរយៈពេលកំណត់នេះ។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ត្រូវធានាបញ្ជូនបញ្ជីអត្រានុកូលដ្ឋានដែលបានអនុវត្តរួចក្នុងទម្រង់ជាក្រដាស មកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ដើម្បីថែទាំ និងរក្សាទុក។

៤. បញ្ជីអត្រានុកូលដ្ឋានក្នុងទម្រង់ជាក្រដាសដែលគ្រប់គ្រងដោយមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវថែទាំ និងរក្សាទុកជាអចិន្ត្រៃយ៍នៅកន្លែងដែលមានសុវត្ថិភាព និងការពារកុំឱ្យមានការខូចខាត ឬការបាត់បង់ ដោយសារអគ្គិភ័យ ទឹកលិច និងគ្រោះមហន្តរាយដទៃទៀត។

៥. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវធានាថារាល់បញ្ជីក្នុងទម្រង់ជាអេឡិចត្រូនិកទាំងអស់ត្រូវបានចម្លងទុក ជារៀងរាល់ថ្ងៃ និងត្រូវមានម៉ាស៊ីនមេសម្រាប់ចម្លងទុកឯកសារមួយច្បាប់ទៀតដែលដូចគ្នាទាំងស្រុងនៅកន្លែងផ្សេងទៀត និងត្រូវថែទាំតាមបទដ្ឋានបច្ចេកទេស និងមានសុវត្ថិភាពខ្ពស់ ដើម្បីការពារពីការខូចខាត ឬការបាត់បង់ដោយសារអគ្គិភ័យ ទឹកលិច និងគ្រោះមហន្តរាយដទៃទៀត។

ផ្នែកទី៣
នីតិវិធី និងពេលវេលានៃការបញ្ជូនបញ្ជី និងរបាយការណ៍ស្តីពីអត្រានុកូលដ្ឋាន

ប្រការ៤៦.- នីតិវិធី និងពេលវេលានៃការបញ្ជូនបញ្ជី និងរបាយការណ៍អត្រានុកូលដ្ឋាន

ការបញ្ជូនបញ្ជី និងរបាយការណ៍អត្រានុកូលដ្ឋានត្រូវអនុវត្តតាមនីតិវិធី និងពេលវេលាដូចខាងក្រោម៖

១. បញ្ជី និងរបាយការណ៍អត្រានុកូលដ្ឋានជាអេឡិចត្រូនិក ត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិ ទៅកាន់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន នៅពេលចុះបញ្ជីអត្រានុកូលដ្ឋានរួចរាល់។

២. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ត្រូវធានាបញ្ជូនបញ្ជីអត្រានុកូលដ្ឋានជាក្រដាស មកនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៅរៀងរាល់ដំណាច់ឆ្នាំនីមួយៗ។

៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ត្រីអត្រានុ-កូលដ្ឋាន ថ្នាក់រាជធានី ខេត្ត និងមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវរៀបចំរបាយការណ៍ស្តីពីអត្រានុកូលដ្ឋានប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំនវមាស និងប្រចាំឆ្នាំ និងបញ្ជូនរបាយការណ៍ទាំងនេះតាមឋានានុក្រមនៃកិច្ចការរដ្ឋបាល។

ទម្រង់នៃរបាយការណ៍ស្តីពីអត្រានុកូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ ជា**ឧបសម្ព័ន្ធទី២៦** នៃប្រកាសនេះ។

ទម្រង់នៃរបាយការណ៍ស្តីពីអត្រានុកូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជា**ឧបសម្ព័ន្ធទី២៧** នៃប្រកាសនេះ។

ទម្រង់នៃរបាយការណ៍ស្តីពីអត្រានុកូលដ្ឋានរបស់រដ្ឋបាលរាជធានី ខេត្ត ជា**ឧបសម្ព័ន្ធទី២៨** នៃប្រកាសនេះ។

ទម្រង់នៃរបាយការណ៍ស្តីពីអត្រានុកូលដ្ឋានរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ជា**ឧបសម្ព័ន្ធទី២៩** នៃប្រកាសនេះ។

ជំពូកទី១៣
បណ្តឹងមិនសុខចិត្ត
ផ្នែកទី១
បុគ្គលដែលអាចដាក់ពាក្យបណ្តឹងមិនសុខចិត្ត

ប្រការ៩៧.- បុគ្គលដែលអាចដាក់ពាក្យបណ្តឹងមិនសុខចិត្ត

បុគ្គលដែលបានស្នើសុំទៅមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីចុះបញ្ជីព្រឹត្តិការណ៍ជីវិត ឬកែតម្រូវបញ្ជីអត្រានុកូលដ្ឋាន ឬសំណើផ្សេងៗទៀត ដូចបានកំណត់ក្នុងប្រកាសនេះ និងប្រកាសពាក់ព័ន្ធនឹងកែតម្រូវបញ្ជីអត្រានុកូលដ្ឋាន អាចដាក់ពាក្យបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានបាន។

ផ្នែកទី២
ទម្រង់ បែបបទ និងការដាក់ពាក្យបណ្តឹងមិនសុខចិត្ត

ប្រការ៩៨.- ទម្រង់ និងព័ត៌មានពាក្យបណ្តឹងមិនសុខចិត្ត

ព័ត៌មានចាំបាច់នៅក្នុងពាក្យបណ្តឹងមិនសុខចិត្ត មានដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួនរបស់អ្នកដាក់ពាក្យបណ្តឹង
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកដាក់ពាក្យបណ្តឹង
- លំនៅឋានបច្ចុប្បន្នរបស់អ្នកដាក់ពាក្យបណ្តឹង

- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់អ្នកដាក់ពាក្យបណ្តឹង (ប្រសិនបើមាន)
- មូលហេតុនៃបណ្តឹងមិនសុខចិត្ត។

ទម្រង់ និងព័ត៌មានផ្សេងទៀតនៃពាក្យបណ្តឹងមិនសុខចិត្តជាក្រដាស និង/ឬអេឡិចត្រូនិក ជា**ឧបសម្ព័ន្ធទី៣០** នៃប្រកាសនេះ។

ករណីពាក្យបណ្តឹងមិនសុខចិត្តក្នុងទម្រង់ជាអេឡិចត្រូនិក អាចបន្ថែមខ្ទង់ទិន្នន័យសម្រាប់បម្រើឱ្យការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ប្រការ៩៩.- ទម្រង់ និងព័ត៌មានសេចក្តីសម្រេចស្តីពីបណ្តឹងមិនសុខចិត្ត

ការដោះស្រាយបណ្តឹងមិនសុខចិត្តពាក់ព័ន្ធនឹងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវចេញសេចក្តីសម្រេចស្តីពីការដោះស្រាយបណ្តឹងមិនសុខចិត្ត ឬការបដិសេធបណ្តឹងមិនសុខចិត្ត ដូចបានកំណត់នៅក្នុងប្រកាសនេះ។

ទម្រង់ និងព័ត៌មាននៃសេចក្តីសម្រេចស្តីពីការដោះស្រាយបណ្តឹងមិនសុខចិត្ត ឬការបដិសេធបណ្តឹងមិនសុខចិត្តរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ជា**ឧបសម្ព័ន្ធទី៣១** នៃប្រកាសនេះ។

ប្រការ១០០.- ទីកន្លែង និងការដាក់ពាក្យបណ្តឹងមិនសុខចិត្ត

បុគ្គលដែលមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដាក់ពាក្យបណ្តឹងនៅទីកន្លែងដែលមានឋានានុក្រមខ្ពស់ជាងមួយថ្នាក់ដូចបានកំណត់ខាងក្រោម៖

- ករណីមិនសុខចិត្តនឹងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ត្រូវដាក់ពាក្យបណ្តឹងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ករណីមិនសុខចិត្តនឹងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យបណ្តឹងនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- ករណីមិនសុខចិត្តនឹងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវដាក់ពាក្យបណ្តឹងនៅរដ្ឋបាលរាជធានី ខេត្ត
- ករណីមិនសុខចិត្តនឹងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ត្រូវដាក់ពាក្យបណ្តឹងនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- ករណីមិនសុខចិត្តនឹងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវដាក់ពាក្យបណ្តឹងនៅក្រសួងមហាផ្ទៃ។

ការដាក់ពាក្យបណ្តឹងមិនសុខចិត្ត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើ មិនរារាំងដល់ការដាក់ពាក្យបណ្តឹងទៅតុលាការដោយផ្ទាល់ឡើយ។

ពាក្យបណ្តឹងមិនសុខចិត្ត ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមរយៈការផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។

ផ្នែកទី៣
ឯកសារភ្ជាប់សម្រាប់ដាក់ពាក្យបណ្តឹងមិនសុខចិត្ត

ប្រការ១០១.- ឯកសារភ្ជាប់សម្រាប់ដាក់ពាក្យបណ្តឹងមិនសុខចិត្ត

ឯកសារភ្ជាប់សម្រាប់ដាក់ពាក្យបណ្តឹងមិនសុខចិត្ត ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ឯកសារអត្តសញ្ញាណរបស់អ្នកដាក់ពាក្យបណ្តឹង

ខ- បង្កាន់ដៃទទួលពាក្យ (ប្រសិនបើមាន)

គ- សេចក្តីសម្រេចស្តីពីការបដិសេធបណ្តឹងមិនសុខចិត្តរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច

ឃ- ឯកសារដែលជាកម្មវត្ថុនៃការស្នើសុំ។

ផ្នែកទី៤
នីតិវិធីនៃការដោះស្រាយបណ្តឹងមិនសុខចិត្ត

ប្រការ១០២.- នីតិវិធីនៃការដោះស្រាយបណ្តឹងមិនសុខចិត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ការដោះស្រាយបណ្តឹងមិនសុខចិត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលពាក្យបណ្តឹងមិនសុខចិត្តនឹងការចាត់ចែងរួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មន្ត្រីទទួលបន្ទុកដោះស្រាយពាក្យបណ្តឹងមិនសុខចិត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យផ្ទៀងផ្ទាត់ពាក្យសុំ និងឯកសារភ្ជាប់ រួចបញ្ជូនទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យសម្រេចក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

២. ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ បដិសេធបណ្តឹងមិនសុខចិត្តរបស់អ្នកដាក់ពាក្យបណ្តឹង ត្រូវចេញសេចក្តីសម្រេចស្តីពីការបដិសេធបណ្តឹងមិនសុខចិត្ត ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

៣. ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មិនបានឆ្លើយតប ឬបដិសេធបណ្តឹងមិនសុខចិត្តក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ អ្នកដាក់ពាក្យបណ្តឹង អាចធ្វើបណ្តឹងឧបាស្រ័យទៅរដ្ឋបាលរាជធានី ខេត្ត។

ប្រការ១០៣.- នីតិវិធីនៃការដោះស្រាយបណ្តឹងមិនសុខចិត្តនៅរដ្ឋបាលរាជធានី ខេត្ត

ការដោះស្រាយបណ្តឹងមិនសុខចិត្តនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលពាក្យបណ្តឹងមិនសុខចិត្តនឹងការចាត់ចែងរួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ត្រីទទួលបន្ទុកដោះស្រាយពាក្យបណ្តឹងមិនសុខចិត្តនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវពិនិត្យផ្ទៀងផ្ទាត់ពាក្យបណ្តឹង និងឯកសារភ្ជាប់ រួចបញ្ជូនទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ដើម្បីពិនិត្យសម្រេចក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

២. ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត បដិសេធបណ្តឹងមិនសុខចិត្តរបស់អ្នកដាក់ពាក្យបណ្តឹង ត្រូវចេញសេចក្តីសម្រេចស្តីពីការបដិសេធបណ្តឹងមិនសុខចិត្ត ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

៣. ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត មិនបានឆ្លើយតប ឬបដិសេធបណ្តឹងមិនសុខចិត្ត ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ អ្នកដាក់ពាក្យបណ្តឹង អាចធ្វើបណ្តឹងឧបាស្រ័យទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

ប្រការ១០៤.- នីតិវិធីនៃការដោះស្រាយបណ្តឹងមិនសុខចិត្ត នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

ការដោះស្រាយបណ្តឹងមិនសុខចិត្តនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

១. បន្ទាប់ពីទទួលពាក្យបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋាន ប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត មន្ត្រីទទួលបន្ទុកដោះស្រាយពាក្យបណ្តឹងមិនសុខចិត្តនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យផ្ទៀងផ្ទាត់ពាក្យសុំ និងឯកសារភ្ជាប់ រួចបញ្ជូនទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីពិនិត្យសម្រេចក្នុងរយៈពេល ១៤(ដប់បួន)ថ្ងៃ នៃថ្ងៃធ្វើការ។

២. ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ បដិសេធបណ្តឹងមិនសុខចិត្តរបស់អ្នកដាក់ពាក្យបណ្តឹង ត្រូវចេញសេចក្តីសម្រេចស្តីពីការបដិសេធបណ្តឹងមិនសុខចិត្ត ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ ក្នុងរយៈពេល ១៤(ដប់បួន)ថ្ងៃ នៃថ្ងៃធ្វើការ។

៣. ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មិនបានឆ្លើយតប ឬបដិសេធបណ្តឹងមិនសុខចិត្ត ក្នុងរយៈពេល ១៤(ដប់បួន)ថ្ងៃ នៃថ្ងៃធ្វើការ អ្នកដាក់ពាក្យបណ្តឹង អាចធ្វើបណ្តឹងឧបាស្រ័យទៅក្រសួងមហាផ្ទៃ។

ប្រការ១០៥.- ដំណើរការដោះស្រាយបណ្តឹងមិនសុខចិត្តនៅក្រសួងមហាផ្ទៃ

ការដោះស្រាយបណ្តឹងមិនសុខចិត្តនៅក្រសួងមហាផ្ទៃ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បន្ទាប់ពីទទួលពាក្យបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្រសួងមហាផ្ទៃ ត្រូវពិនិត្យផ្ទៀងផ្ទាត់ពាក្យបណ្តឹង និងឯកសារភ្ជាប់ និងពិនិត្យដោះស្រាយក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។

២. ករណីអ្នកដាក់ពាក្យបណ្តឹង មិនសុខចិត្តនឹងការសម្រេចរបស់ក្រសួងមហាផ្ទៃ អាចដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ឬការបដិសេធនោះ។

ប្រការ១០៦.- ការអនុវត្តសេចក្តីសម្រេចស្តីពីដំណោះស្រាយបណ្តឹងមិនសុខចិត្តរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច

បន្ទាប់ពីទទួលបានសេចក្តីសម្រេចស្តីពីដំណោះស្រាយបណ្តឹងមិនសុខចិត្តរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវអនុវត្តសេចក្តីសម្រេចនោះឱ្យបានឆាប់រហ័ស ជូនអ្នកដាក់ពាក្យបណ្តឹង។

ផ្នែកទី៥
ទណ្ឌកម្មរដ្ឋបាល

ប្រការ១០៧.- ទណ្ឌកម្មរដ្ឋបាល

ករណីរកឃើញកំហុសមន្ត្រីទទួលការងារអត្រានុកូលដ្ឋាន ឬមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចពាក់ព័ន្ធនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម៖

- ត្រូវធ្វើការណែនាំ និងកែតម្រូវកំហុស និង/ឬ
- អនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីការដាក់ទណ្ឌកម្មរដ្ឋបាល។

បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មចំពោះមន្ត្រីទទួលការងារអត្រានុកូលដ្ឋាន និងមន្ត្រីអត្រានុកូលដ្ឋានដែលបានប្រព្រឹត្តនូវកំហុសពាក់ព័ន្ធនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង ត្រូវអនុវត្តតាមលិខិតបទដ្ឋានរបស់ស្ថាប័ន ឬអង្គភាពកំណត់។

ជំពូកទី១៤
ការដាក់ដំណើរការ ការកំណត់ស្តង់ដាបច្ចេកទេសសម្រាប់អនុវត្តប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងសៀវភៅណែនាំស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធអេឡិចត្រូនិក

ប្រការ១០៨.- ការដាក់ដំណើរការ និងការកំណត់ស្តង់ដាបច្ចេកទេសសម្រាប់អនុវត្តប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន

ការដាក់ដំណើរការប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ការកំណត់ស្តង់ដាបច្ចេកទេសសម្រាប់អនុវត្តប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

ប្រការ១០៩.- ការណែនាំលម្អិតស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធអេឡិចត្រូនិក

ការណែនាំលម្អិតស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវកំណត់នៅក្នុងសៀវភៅណែនាំស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន តាមប្រព័ន្ធអឡិចត្រូនិករបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

ជំពូកទី១៥
អន្តរប្បញ្ញត្តិ

ប្រការ១១០.- ការអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋាន

រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលរាជធានី ខេត្ត ដែលពុំទាន់បានភ្ជាប់ទៅនឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ត្រូវបន្តអនុវត្តការងារអត្រានុកូលដ្ឋាន ស្របតាមនីតិវិធីដូចបានកំណត់នៅក្នុងអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន និងលិខិតបទដ្ឋានគតិយុត្តជាធរមាន រហូតដល់មានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

ជំពូកទី១៦
អវសានប្បញ្ញត្តិ

ប្រការ១១១.- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១១២.- ការអនុវត្ត

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានកស្ទុការនិងហិរញ្ញវត្ថុ និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ៣យ ៧ កើត ខែ ៤ត ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២៦
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

អតិសន្តិបណ្ឌិត ស សុខា

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ធកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ជូចប្រការ១១២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

បញ្ជីកំណើតរស់

Live Birth Record

ពំតីមានអ្នកកើត			
នាមត្រកូល		Surname	
នាមខ្លួន		First Name	
ភេទ		Sex	
សញ្ជាតិ		Nationality	
ថ្ងៃ ខែ ឆ្នាំកំណើត		Date of Birth	
ទីកន្លែងកំណើត		Place of Birth	
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី		Date of Reg.	
ទីកន្លែងចុះបញ្ជី		Place of Reg.	
ម៉ោងកើត			
ទម្ងន់ពេលកើត			
កូនទី			
ប្រភេទកំណើត			
ប្រភេទទីកន្លែងកំណើត			
អ្នកផ្តល់សេវាសម្រាលកូន			
ពំតីមានឪពុកម្តាយ	**ឪពុក**	**ម្តាយ**	
នាមត្រកូល និងនាមខ្លួន			
សញ្ជាតិ			
ថ្ងៃ ខែ ឆ្នាំកំណើត			
ស្ថានភាព (រស់ ឬស្លាប់)			
ទីកន្លែងកំណើត			
លំនៅឋានបច្ចុប្បន្ន			
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល			

ព័ត៌មានអ្នករាយការណ៍			
ត្រូវជាអ្វីនឹងអ្នកកើត			
នាមត្រកូល និងនាមខ្លួន		ភេទ	
ថ្ងៃ ខែ ឆ្នាំកំណើត		សញ្ជាតិ	
លំនៅឋានបច្ចុប្បន្ន			
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល			



លេខចុះបញ្ជី: CBXX-XXXXX
លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល
UIC: XXX-XXX-XXXX

ថ្ងៃ..... ខែ..... ឆ្នាំ..... ស័ក ព.ស. ២៥.....
ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....

មន្ត្រីអន្តោនុកូលដ្ឋាន

ស្លាមមេដៃស្តាំអ្នករាយការណ៍

ឈ្មោះ.....

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ...៣០៦៨.....ប្រក ចុះថ្ងៃទី...៣៤.ខែ...៥...ឆ្នាំ...៣០៣៦...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



Kingdom of Cambodia
Nation Religion King

បញ្ជីមរណភាព

Death Record

ព័ត៌មានមរណជន			
នាមត្រកូល		Surname	
នាមខ្លួន		First Name	
ភេទ		Sex	
សញ្ជាតិ		Nationality	
ថ្ងៃ ខែ ឆ្នាំកំណើត		Date of Birth	
ទីកន្លែងកំណើត		Place of Birth	
ថ្ងៃ ខែ ឆ្នាំទទួលមរណភាព		Date of Death	
ទីកន្លែងទទួលមរណភាព		Place of Death	
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី		Date of Reg.	
ទីកន្លែងចុះបញ្ជី		Place of Reg.	
ម៉ោងទទួលមរណភាព			
លំនៅឋានបច្ចុប្បន្ន			
ប្រភេទមរណភាព			
ប្រភេទទីកន្លែងមរណភាព			
ស្ថានភាពអាពាហ៍ពិពាហ៍			
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល			
ព័ត៌មានឲ្យពុកម្តាយ	**ឲ្យពុក**	**ម្តាយ**	
នាមត្រកូល និងនាមខ្លួន			
សញ្ជាតិ			
ថ្ងៃ ខែ ឆ្នាំកំណើត			

ស្ថានភាព (រស់ ឬស្លាប់)			
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល			
ព័ត៌មានអ្នករាយការណ៍			
ត្រូវជាអ្វីនឹងមរណជន			
នាមត្រកូល និងនាមខ្លួន		កេទ	
ថ្ងៃ ខែ ឆ្នាំកំណើត		សញ្ជាតិ	
លំនៅឋានបច្ចុប្បន្ន			
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល			



លេខចុះបញ្ជី : CDXX-XXXXX

ថ្ងៃ..... ខែ..... ឆ្នាំ..... ស័ក ព.ស. ២៥.....

ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....

មន្ត្រីអត្រានុកូលដ្ឋាន

ស្នាមមេដៃស្តាំអ្នករាយការណ៍

ឈ្មោះ.....

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ..៣០៦៨.....ប្រក ចុះថ្ងៃទី២៥.ខែ..មីនា...ឆ្នាំ ២០២៣...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

បញ្ជីអាពាហ៍ពិពាហ៍

Marriage Record

ព័ត៌មានប្តី			
នាមត្រកូល		Surname	
នាមខ្លួន		First Name	
សញ្ជាតិ		Nationality	
ថ្ងៃ ខែ ឆ្នាំកំណើត		Date of Birth	
ទីកន្លែងកំណើត		Place of Birth	
លំនៅឋានបច្ចុប្បន្ន			
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល			
ព័ត៌មានប្រពន្ធ			
នាមត្រកូល		Surname	
នាមខ្លួន		First Name	
សញ្ជាតិ		Nationality	
ថ្ងៃ ខែ ឆ្នាំកំណើត		Date of Birth	
ទីកន្លែងកំណើត		Place of Birth	
លំនៅឋានបច្ចុប្បន្ន			
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល			
បណ្ណប្រកាស និងការចុះបញ្ជីអាពាហ៍ពិពាហ៍			
លេខ ថ្ងៃ ខែ ឆ្នាំបណ្ណប្រកាស អាពាហ៍ពិពាហ៍			
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី		Date of Reg.	
ទីកន្លែងចុះបញ្ជី		Place of Reg.	
ព័ត៌មានឪពុកម្តាយមាតាប្តី	**ឪពុក**		**ម្តាយ**
នាមត្រកូល និងនាមខ្លួន			

សញ្ជាតិ		
ថ្ងៃ ខែ ឆ្នាំកំណើត		
ស្ថានភាព (រស់ ឬស្លាប់)		
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល		
ព័ត៌មានឪពុកម្តាយខាងប្រពន្ធ	**ឪពុក**	**ម្តាយ**
នាមត្រកូល និងនាមខ្លួន		
សញ្ជាតិ		
ថ្ងៃ ខែ ឆ្នាំកំណើត		
ស្ថានភាព (រស់ ឬស្លាប់)		
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល		
ព័ត៌មានសាក្សី	**សាក្សីទី១**	**សាក្សីទី២**
នាមត្រកូល និងនាមខ្លួន		
ភេទ		
សញ្ជាតិ		
ថ្ងៃ ខែ ឆ្នាំកំណើត		
លំនៅឋានបច្ចុប្បន្ន		
លេខកូដសម្គាល់ អត្តសញ្ញាណបុគ្គល		

លេខចុះបញ្ជី : CMXX-XXXXX

ថ្ងៃ..... ខែ..... ឆ្នាំ..... ស័ក ព.ស. ២៥.....

ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....

មន្ត្រីអត្រានុកូលដ្ឋាន

ស្នាមមេដៃស្តាំ

ប្តី ប្រពន្ធ សាក្សីទី១ សាក្សីទី២

ឈ្មោះ..... ....

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ.....ប្រក ចុះថ្ងៃទី..ខែ..ឆ្នាំ..ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

សំបុត្រកំណើត
Certificate of Birth

នាមត្រកូល	**Surname**
នាមខ្លួន	**First Name**
ភេទ	**Sex**
សញ្ជាតិ	**Nationality**
ថ្ងៃ ខែ ឆ្នាំកំណើត	**Date of Birth**
ទីកន្លែងកំណើត	**Place of Birth**
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី	**Date of Reg.**
ទីកន្លែងចុះបញ្ជី	**Place of Reg.**

ឈ្មោះឪពុក
សញ្ជាតិ
ថ្ងៃ ខែ ឆ្នាំកំណើត
ទីកន្លែងកំណើត

ឈ្មោះម្តាយ
សញ្ជាតិ
ថ្ងៃ ខែ ឆ្នាំកំណើត
ទីកន្លែងកំណើត

ព.ស. ២៥

លេខចុះបញ្ជី:CBXX-XXXXX
លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល
UIC: XXX-XXX-XXXX

ថ្ងៃ ខែ ឆ្នាំ
ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ២០
មន្ត្រីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ...៣០៦៨.....ប្រក ចុះថ្ងៃទី...៣៤...ខែ...៥...ឆ្នាំ...២០២៦...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



Kingdom of Cambodia
Nation Religion King

សំបុត្រមរណភាព
Certificate of Death

នាមត្រកូល	Surname
នាមខ្លួន	First Name
ភេទ	Sex
សញ្ជាតិ	Nationality
ថ្ងៃ ខែ ឆ្នាំកំណើត	Date of Birth
ទីកន្លែងកំណើត	Place of Birth
ថ្ងៃ ខែ ឆ្នាំទទួលមរណភាព	Date of Death
ទីកន្លែងទទួលមរណភាព	Place of Death
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី	Date of Reg.
ទីកន្លែងចុះបញ្ជី	Place of Reg.



លេខចុះបញ្ជី:CDXX-XXXXX



ថ្ងៃ ខែ ឆ្នាំ ព.ស.២៥
ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ២០
មន្ត្រីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ...៣៦៨៨.....ប្រក ចុះថ្ងៃទី...៣៤...ខែ...៥...ឆ្នាំ...៣៦៣៨...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



Kingdom of Cambodia
Nation Religion King

សំបុត្រអាពាហ៍ពិពាហ៍
Certificate of Marriage

នាមត្រកូលប្តី	Husband Surname
នាមខ្លួនប្តី	Husband First Name
សញ្ជាតិ	Nationality
ថ្ងៃ ខែ ឆ្នាំកំណើត	Date of Birth
ទីកន្លែងកំណើត	Place of Birth
នាមត្រកូលប្រពន្ធ	Wife Surname
នាមខ្លួនប្រពន្ធ	Wife First Name
សញ្ជាតិ	Nationality
ថ្ងៃ ខែ ឆ្នាំកំណើត	Date of Birth
ទីកន្លែងកំណើត	Place of Birth
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី	Date of Reg.
ទីកន្លែងចុះបញ្ជី	Place of Reg.



លេខចុះបញ្ជី: CMXX-XXXXX

ថ្ងៃ ខែ ឆ្នាំ ព.ស. ២៥

ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ២០

មន្ត្រីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី៧ នៃប្រកាសលេខ...៣០៦៨.....ប្រក ចុះថ្ងៃទី...៣៤...ខែ...៥...ឆ្នាំ...៣០៣៦...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



Kingdom of Cambodia
Nation Religion King

សេចក្តីចម្លងសំបុត្រកំណើត
Copy of Birth Certificate

នាមត្រកូល	Surname
នាមខ្លួន	First Name
ភេទ	Sex
សញ្ជាតិ	Nationality
ថ្ងៃ ខែ ឆ្នាំកំណើត	Date of Birth
ទីកន្លែងកំណើត	Place of Birth
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី	Date of Reg.
ទីកន្លែងចុះបញ្ជី	Place of Reg.

ឈ្មោះឪពុក
សញ្ជាតិ
ថ្ងៃ ខែ ឆ្នាំកំណើត
ទីកន្លែងកំណើត

ឈ្មោះម្តាយ
សញ្ជាតិ
ថ្ងៃ ខែ ឆ្នាំកំណើត
ទីកន្លែងកំណើត



លេខ : ស.ប.ក

លេខចុះបញ្ជី:CBXX-XXXXX
លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល
UIC: XXX-XXX-XXXX



ថ្ងៃ ខែ ឆ្នាំ ព.ស. ២៥
ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ២០
មន្ត្រីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី៨ នៃប្រកាសលេខ...៣៦៦៨.....ប្រក ចុះថ្ងៃទី...២៩...ខ្នាំ...៣៦...ឆ្នាំ...២៦៣៦...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

សេចក្តីចម្លងសំបុត្រមរណភាព
Copy of Death Certificate

នាមត្រកូល	**Surname**
នាមខ្លួន	**First Name**
ភេទ	**Sex**
សញ្ជាតិ	**Nationality**
ថ្ងៃ ខែ ឆ្នាំកំណើត	**Date of Birth**
ទីកន្លែងកំណើត	**Place of Birth**
ថ្ងៃ ខែ ឆ្នាំទទួលមរណភាព	**Date of Death**
ទីកន្លែងទទួលមរណភាព	**Place of Death**
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី	**Date of Reg.**
ទីកន្លែងចុះបញ្ជី	**Place of Reg.**

លេខ : ស.ប.ម

លេខចុះបញ្ជី:CDXX-XXXXX

ថ្ងៃ ខែ ឆ្នាំ ព.ស. ២៥
ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ២០

មន្ត្រីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី៩ នៃប្រកាសលេខ...៣៦៨៨.....ប្រក ចុះថ្ងៃទី...២៤...ខែ...មិនា...ឆ្នាំ...២០២៦...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
Copy of Marriage Certificate

នាមត្រកូលប្តី	**Husband Surname**
នាមខ្លួនប្តី	**Husband First Name**
សញ្ជាតិ	**Nationality**
ថ្ងៃ ខែ ឆ្នាំកំណើត	**Date of Birth**
ទីកន្លែងកំណើត	**Place of Birth**
នាមត្រកូលប្រពន្ធ	**Wife Surname**
នាមខ្លួនប្រពន្ធ	**Wife First Name**
សញ្ជាតិ	**Nationality**
ថ្ងៃ ខែ ឆ្នាំកំណើត	**Date of Birth**
ទីកន្លែងកំណើត	**Place of Birth**
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី	**Date of Reg.**
ទីកន្លែងចុះបញ្ជី	**Place of Reg.**

លេខ : ស.ប.អ

លេខចុះបញ្ជី: **CMXX-XXXXX**

ថ្ងៃ ខែ ឆ្នាំ ព.ស. ២៥
ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ២០

មន្ត្រីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី១០ នៃប្រកាសលេខ..៣០៦៨.....ប្រក ចុះថ្ងៃទី..២៩.ខែ...៥...ឆ្នាំ..២០២៦...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



Kingdom of Cambodia
Nation Religion King

សម្រង់បញ្ជីកំណើតរស់

Extract of Live Birth Record

ពំតីមានអ្នកកើត			
នាមត្រកូល		Surname	
នាមខ្លួន		First Name	
ភេទ		Sex	
សញ្ជាតិ		Nationality	
ថ្ងៃ ខែ ឆ្នាំកំណើត		Date of Birth	
ទីកន្លែងកំណើត		Place of Birth	
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី		Date of Reg.	
ទីកន្លែងចុះបញ្ជី		Place of Reg.	
ម៉ោងកើត			
ទម្ងន់ពេលកើត			
កូនទី			
ប្រភេទកំណើត			
ប្រភេទទីកន្លែងកំណើត			
អ្នកផ្តល់សេវាសម្រាលកូន			
ពំតីមានឲ្ងីពុកម្តាយ	**ឲ្ងីពុក**	**ម្តាយ**	
នាមត្រកូល និងនាមខ្លួន			
សញ្ជាតិ			
ថ្ងៃ ខែ ឆ្នាំកំណើត			
ស្ថានភាព (រស់ ឬស្លាប់)			
ទីកន្លែងកំណើត			
លំនៅឋានបច្ចុប្បន្ន			



ព័ត៌មានអ្នកាយការណ៍			
ត្រូវជាអ្វីជាមួយអ្នកកើត			
នាមត្រកូល និងនាមខ្លួន		ភេទ	
ថ្ងៃ ខែ ឆ្នាំកំណើត		សញ្ជាតិ	
លំនៅឋានបច្ចុប្បន្ន			

លេខចុះបញ្ជី : CBXX-XXXXX

លេខ : ..... ស.ភេ

ថ្ងៃ..... ខែ..... ឆ្នាំ..... ស័ក ព.ស. ២៥.....

ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....

មន្ត្រីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី១១ នៃប្រកាសលេខ...៣០៤៦.....ប្រក ចុះថ្ងៃទី...២៤.ខែ...មិន...ឆ្នាំ...២០២៤...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

សម្រង់បញ្ជីមរណភាព

Extract of Death Record

ព័ត៌មានមរណជន			
នាមត្រកូល		Surname	
នាមខ្លួន		First Name	
ភេទ		Sex	
សញ្ជាតិ		Nationality	
ថ្ងៃ ខែ ឆ្នាំកំណើត		Date of Birth	
ទីកន្លែងកំណើត		Place of Birth	
ថ្ងៃ ខែ ឆ្នាំទទួលមរណភាព		Date of Death	
ទីកន្លែងទទួលមរណភាព		Place of Death	
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី		Date of Reg.	
ទីកន្លែងចុះបញ្ជី		Place of Reg.	
ម៉ោងទទួលមរណភាព			
លំនៅឋានបច្ចុប្បន្ន			
ប្រភេទមរណភាព			
ប្រភេទទីកន្លែងមរណភាព			
ស្ថានភាពអាពាហ៍ពិពាហ៍			
ព័ត៌មានឲ្យពុកម្តាយ	**ឲ្យពុក**	**ម្តាយ**	
នាមត្រកូល និងនាមខ្លួន			
សញ្ជាតិ			
ថ្ងៃ ខែ ឆ្នាំកំណើត			
ស្ថានភាព (រស់ ឬស្លាប់)			

ព័ត៌មានអ្នកឈរការណ៍			
ត្រូវជាអ្វីជាមួយមរណជន			
នាមត្រកូល និងនាមខ្លួន		ភេទ	
ថ្ងៃ ខែ ឆ្នាំកំណើត		សញ្ជាតិ	
លំនៅឋានបច្ចុប្បន្ន			

លេខចុះបញ្ជី : CDXX-XXXXX

លេខ : ..... ស.រ.ម

ថ្ងៃ..... ខែ..... ឆ្នាំ..... ស័ក ព.ស. ២៥.....

ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....

មន្ត្រីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី១២ នៃប្រកាសលេខ...៣០៦៨.....ប្រក ចុះថ្ងៃទី...៣៤...ខែ...៥...ឆ្នាំ...៣០៣៦....ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន
តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

សម្រង់បញ្ជីអាពាហ៍ពិពាហ៍
Extract of Marriage Record

ព័ត៌មានប្តី			
នាមត្រកូល		Surname	
នាមខ្លួន		First Name	
សញ្ជាតិ		Nationality	
ថ្ងៃ ខែ ឆ្នាំកំណើត		Date of Birth	
ទីកន្លែងកំណើត		Place of Birth	
លំនៅឋានបច្ចុប្បន្ន			
ព័ត៌មានប្រពន្ធ			
នាមត្រកូល		Surname	
នាមខ្លួន		First Name	
សញ្ជាតិ		Nationality	
ថ្ងៃ ខែ ឆ្នាំកំណើត		Date of Birth	
ទីកន្លែងកំណើត		Place of Birth	
លំនៅឋានបច្ចុប្បន្ន			
បណ្ណប្រកាស និងការចុះបញ្ជីអាពាហ៍ពិពាហ៍			
លេខ ថ្ងៃ ខែ ឆ្នាំបណ្ណប្រកាស អាពាហ៍ពិពាហ៍			
ថ្ងៃ ខែ ឆ្នាំចុះបញ្ជី		Date of Reg.	
ទីកន្លែងចុះបញ្ជី		Place of Reg.	
ព័ត៌មានឲ្យពុកម្តាយខាងប្តី	**ឲ្យពុក**	**ម្តាយ**	
នាមត្រកូល និងនាមខ្លួន			
សញ្ជាតិ			

ថ្ងៃ ខែ ឆ្នាំកំណើត		
ស្ថានភាព (រស់ ឬស្លាប់)		
ព័ត៌មានឪពុកម្តាយខាងប្រពន្ធ	**ឪពុក**	**ម្តាយ**
នាមត្រកូល និងនាមខ្លួន		
សញ្ជាតិ		
ថ្ងៃ ខែ ឆ្នាំកំណើត		
ស្ថានភាព (រស់ ឬស្លាប់)		
ព័ត៌មានសាក្សី	**សាក្សីទី១**	**សាក្សីទី២**
នាមត្រកូល និងនាមខ្លួន		
ភេទ		
សញ្ជាតិ		
ថ្ងៃ ខែ ឆ្នាំកំណើត		
លំនៅឋានបច្ចុប្បន្ន		

លេខចុះបញ្ជី : CMXX-XXXXX

លេខ : ..... ស.រ.អ

ថ្ងៃ..... ខែ..... ឆ្នាំ..... ស័ក ព.ស. ២៥.....

ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....

មន្ត្រីអន្តោនុកូលដ្ឋាន

ឧបសម្ព័ន្ធទី១៣ នៃប្រកាសលេខ...៣០៦៨.....ប្រក ចុះថ្ងៃទី...២៤.ខែ...៥...ឆ្នាំ...២០២៦...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន

តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យសុំចុះបញ្ជីកំណើតរស់

សូមគោរពជូន		**មន្ត្រីអត្រានុកូលដ្ឋាន**	
កម្មវត្ថុ		សំណើសុំចុះបញ្ជីកំណើតរស់	
ព័ត៌មានឧារក			
នាមត្រកូល		.....	ភេទ ☐ ប្រុស ☐ ស្រី
នាមខ្លួន		.....	
នាមត្រកូល	ជាអក្សរឡាតាំង	.....	កូនទី .....
នាមខ្លួន		.....	
ជនជាតិ		☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់)	
សញ្ជាតិ		☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់)	
ថ្ងៃ ខែ ឆ្នាំកំណើត		ថ្ងៃទី ..... ខែ ..... ឆ្នាំ	
ម៉ោងកើត(២៤ម៉ោង)		ម៉ោង ..... : ..... នាទី	
ប្រភេទទីកន្លែងកំណើត		☐ មន្ទីរពេទ្យជាតិ ☐ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ☐ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ☐ មណ្ឌលសុខភាព ☐ ប៉ុស្តិ៍សុខភាព ☐ មូលដ្ឋានសុខាភិបាលឯកជន ☐ ផ្ទះ ☐ ផ្សេងៗ (សូមបញ្ជាក់)	
ទីកន្លែងកំណើត		☐ ទីកន្លែងកំណើតនៅក្នុងប្រទេស សូមបំពេញព័ត៌មានខាងក្រោម៖ ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	
		☐ ទីកន្លែងកំណើតនៅក្រៅប្រទេស (សូមបញ្ជាក់ឈ្មោះប្រទេស)	
ប្រភេទកំណើត		☐ កូនទោល ☐ ភ្លោះពីរ ☐ ភ្លោះបី ☐ ភ្លោះបួន ☐ ផ្សេងៗ (សូមបញ្ជាក់)	
ព័ត៌មានឲ្ងពុកម្តាយឧារក		**ឲ្ងពុក**	**ម្តាយ**
នាមត្រកូល		.....	.....
នាមខ្លួន		.....	.....
ជនជាតិ		☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់)	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់) .....
សញ្ជាតិ		☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់)	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់) .....
សាសនា		.....	.....
ថ្ងៃ ខែ ឆ្នាំកំណើត		ថ្ងៃទី ..... ខែ ..... ឆ្នាំ	ថ្ងៃទី ..... ខែ ..... ឆ្នាំ .....
ស្ថានភាព(រស់ ឬស្លាប់)		☐ រស់ ☐ ស្លាប់	☐ រស់ ☐ ស្លាប់

ទីកន្លែងកំណើត	ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស .....
លំនៅឋានបច្ចុប្បន្ន	ផ្ទះលេខ ..... ផ្លូវ ..... ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	ផ្ទះលេខ ..... ផ្លូវ ..... ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស .....
កម្រិតវប្បធម៌	☐ មិនបានរៀន ☐ ថ្នាក់បឋមសិក្សា ☐ ថ្នាក់អនុវិទ្យាល័យ ☐ ថ្នាក់វិទ្យាល័យ ☐ ថ្នាក់ឧត្តមសិក្សា ☐ ផ្សេងៗ (សូមបញ្ជាក់)	☐ មិនបានរៀន ☐ ថ្នាក់បឋមសិក្សា ☐ ថ្នាក់អនុវិទ្យាល័យ ☐ ថ្នាក់វិទ្យាល័យ ☐ ថ្នាក់ឧត្តមសិក្សា ☐ ផ្សេងៗ (សូមបញ្ជាក់) .....
មុខរបរ	.....	.....
ស្ថានភាពអាពាហ៍ពិពាហ៍របស់ម្តាយ	☐ មានសំបុត្រអាពាហ៍ពិពាហ៍ ☐ គ្មានសំបុត្រអាពាហ៍ពិពាហ៍	
☐ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ឬ ☐ លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ ☐ លេខលិខិតឆ្លងដែន ឬ ☐ លេខបណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជនបរទេសអន្តោប្រវេសន្ត	.....	.....

ការចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ១ឆ្នាំ ឬក្រោយផុតរយៈពេលអនុគ្រោះ១ឆ្នាំ

☐ ករណីការចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ១ឆ្នាំ បន្ទាប់ពីកំណើតរស់បានកើតឡើង សូមបញ្ជាក់មូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេល៣០ថ្ងៃ : .....

☐ ករណីការចុះបញ្ជីកំណើតរស់ក្រោយផុតរយៈពេលអនុគ្រោះ១ឆ្នាំ បន្ទាប់ពីកំណើតរស់បានកើតឡើង

១) សូមបញ្ជាក់មូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេលអនុគ្រោះ១ឆ្នាំ :

.....

២) ការធានាអះអាងសាក្សី១រូបដែលដឹងអំពីព្រឹត្តិការណ៍ សូមបំពេញព័ត៌មានសាក្សីដូចខាងក្រោម៖

នាមត្រកូល	.....	ភេទ ☐ ប្រុស ☐ ស្រី
នាមខ្លួន	.....	
ជនជាតិ	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់)	
សញ្ជាតិ	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់)	
ថ្ងៃ ខែ ឆ្នាំកំណើត	ថ្ងៃទី ..... ខែ ..... ឆ្នាំ	
លំនៅឋានបច្ចុប្បន្ន	ផ្ទះលេខ ..... ផ្លូវ ..... ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	

☐ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ឬ ☐ លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ ☐ លេខលិខិតឆ្លងដែន ឬ ☐ លេខបណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជនបរទេសអន្តោប្រវេសន្ត	.....
ស្នាមមេដៃស្តាំសាក្សី	ថ្ងៃ ..... ខែ ..... ឆ្នាំ ..... ស័ក ព.ស. ២៥..... ..... ថ្ងៃទី ..... ខែ ..... ឆ្នាំ២០..... ឈ្មោះ .....

ព័ត៌មានអ្នករាយការណ៍

ត្រូវជាអ្វីនឹងទារក : ☐ ម្តាយ ☐ ឪពុក ☐ ផ្សេងៗ (សូមបញ្ជាក់) .....

ប្រសិនបើអ្នករាយការណ៍មិនមែនជាម្តាយឬឪពុក សូមបំពេញព័ត៌មានដូចខាងក្រោម៖

នាមត្រកូល	.....	ភេទ ☐ ប្រុស ☐ ស្រី
នាមខ្លួន	.....	
ជនជាតិ	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់)	
សញ្ជាតិ	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់)	
ថ្ងៃ ខែ ឆ្នាំកំណើត	ថ្ងៃទី ..... ខែ ..... ឆ្នាំ	
លំនៅឋានបច្ចុប្បន្ន	ផ្ទះលេខ ..... ផ្លូវ ..... ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	
☐ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ឬ ☐ លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ ☐ លេខលិខិតឆ្លងដែន ឬ ☐ លេខបណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជនបរទេសអន្តោប្រវេសន្ត	.....	
លេខទូរស័ព្ទអ្នករាយការណ៍	.....	

ថ្ងៃ ..... ខែ ..... ឆ្នាំ ..... ស័ក ព.ស. ២៥..... ..... ថ្ងៃទី ..... ខែ ..... ឆ្នាំ២០..... **មន្ត្រីទទួលពាក្យ** ឈ្មោះ	ខ្ញុំសូមបញ្ជាក់ថារាល់ព័ត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវប្រាកដមែន។ ថ្ងៃ ..... ខែ ..... ឆ្នាំ ..... ស័ក ព.ស. ២៥..... ..... ថ្ងៃទី ..... ខែ ..... ឆ្នាំ២០..... ស្នាមមេដៃស្តាំអ្នករាយការណ៍ ឈ្មោះ .....

ឯកសារត្រាប់សម្រាប់ចុះបញ្ជីកំណើតរស់ ÷

១. ឯកសារបញ្ជាក់អំពីកំណើតរស់

- ☐ លិខិតជូនដំណឹងអំពីកំណើតរស់ចេញដោយមូលដ្ឋានសុខាភិបាល ឬ
- ☐ បណ្ណសុខភាពកុមារ ឬ
- ☐ លិខិតបញ្ជាក់អំពីកំណើតរស់ចេញដោយមេភូមិនៃទីកន្លែងដែលទារកបានកើត ឬ
- ☐ សំបុត្រកំណើតពីប្រទេសដែលទារកបានកើត ឬ
- ☐ ឯកសារភស្តុតាងផ្សេងទៀត ដែលបញ្ជាក់អំពីកំណើតរស់។

២. ឯកសារអត្តសញ្ញាណរបស់ម្តាយ ឪពុក សាក្សី និងអ្នករាយការណ៍

☐ សម្រាប់ប្រជាពលរដ្ឋខ្មែរ

- ☐ សំបុត្រកំណើត ឬ ☐សេចក្តីចម្លងសំបុត្រកំណើត : ☐ឪពុក ☐ម្តាយ ☐សាក្សី ☐អ្នករាយការណ៍ ឬ
- ☐ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ : ☐ឪពុក ☐ម្តាយ ☐សាក្សី ☐អ្នករាយការណ៍ ឬ
- ☐ លិខិតឆ្លងដែន : ☐ឪពុក ☐ម្តាយ ☐សាក្សី ☐អ្នករាយការណ៍ ឬ
- ☐ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល : ☐ឪពុក ☐ម្តាយ ☐សាក្សី ☐អ្នករាយការណ៍ និង
- ☐ សៀវភៅស្នាក់នៅ ☐សៀវភៅគ្រួសារ ឬ☐លិខិតបញ្ជាក់ទីលំនៅ ឬ☐ឯកសារផ្សេងទៀតដែលបញ្ជាក់អំពីការស្នាក់នៅ : ☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍

☐ សម្រាប់ជនបរទេស

- ☐ សំបុត្រកំណើត : ☐ឪពុក ☐ម្តាយ ☐សាក្សី ☐អ្នករាយការណ៍ ឬ
- ☐ លិខិតឆ្លងដែន : ☐ឪពុក ☐ម្តាយ ☐សាក្សី ☐អ្នករាយការណ៍ ឬ
- ☐ បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត : ☐ឪពុក ☐ម្តាយ ☐សាក្សី ☐អ្នករាយការណ៍ ឬ
- ☐ ឯកសារអត្តសញ្ញាណផ្សេងទៀតចេញដោយប្រទេសសាមី ឬស្ថានទូត : ☐ឪពុក ☐ម្តាយ ☐សាក្សី ☐អ្នករាយការណ៍ និង
- ☐ សៀវភៅស្នាក់នៅ ឬ☐លិខិតបញ្ជាក់ទីលំនៅ ឬ☐ឯកសារផ្សេងទៀតដែលបញ្ជាក់អំពីការស្នាក់នៅ : ☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍

៣.ឯកសារបញ្ជាក់អំពីបិតុភាព

- ☐ សំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកនិងម្តាយ ឬ ☐ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកនិងម្តាយ ឬ
- ☐ ទម្រង់ទទួលស្គាល់ដោយស្ម័គ្រចិត្ត ឬ
- ☐ សេចក្តីសម្រេចរបស់តុលាការទទួលស្គាល់កូន ឬ
- ☐ ការទទួលស្គាល់ដោយស្ម័គ្រចិត្តនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ជាមួយនឹងការយល់ព្រមពីម្តាយ នៅពេលចុះបញ្ជី

ឧបសម្ព័ន្ធទី១៤ នៃប្រកាសលេខ...៣៦៨៨.....ប្រក ចុះថ្ងៃទី...២៤...ខែ...មិ...ឆ្នាំ...២០២៦...ស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន

តាមប្រព័ន្ធអេឡិចត្រូនិក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យសុំចុះបញ្ជីមរណភាព

សូមគោរពជូន		**មន្ត្រីអត្រានុកូលដ្ឋាន**	
កម្មវត្ថុ		សំណើសុំចុះបញ្ជីមរណភាព	
ព័ត៌មានមរណជន			
នាមត្រកូល		.....	ភេទ ☐ ប្រុស ☐ ស្រី
នាមខ្លួន		.....	
នាមត្រកូល	ជាអក្សរឡាតាំង	.....	
នាមខ្លួន		.....	
ជនជាតិ		☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់)	
សញ្ជាតិ		☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ(សូមបញ្ជាក់)	
សាសនា		.....	
ថ្ងៃ ខែ ឆ្នាំកំណើត		ថ្ងៃទី..... ខែ..... ឆ្នាំ.....	
ទីកន្លែងកំណើត		☐ ទីកន្លែងកំណើតនៅក្នុងប្រទេស សូមបំពេញព័ត៌មានខាងក្រោម៖ ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	
		☐ ទីកន្លែងកំណើតក្រៅប្រទេស (សូមបញ្ជាក់ឈ្មោះប្រទេស)	
ថ្ងៃ ខែ ឆ្នាំទទួលមរណភាព		ថ្ងៃទី..... ខែ..... ឆ្នាំ.....	
ម៉ោងទទួលមរណភាព(២៤ម៉ោង)		ម៉ោង.....:.....នាទី	
ប្រភេទទីកន្លែងទទួលមរណភាព		☐មន្ទីរពេទ្យជាតិ ☐មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ☐មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ☐ មណ្ឌលសុខភាព ☐ ប៉ុស្តិ៍សុខភាព ☐ មូលដ្ឋានសុខាភិបាលឯកជន ☐ ផ្ទះ ☐ ផ្សេងៗ (សូមបញ្ជាក់)	
ទីកន្លែងទទួលមរណភាព		☐ ទីកន្លែងមរណភាពនៅក្នុងប្រទេស សូមបំពេញព័ត៌មានខាងក្រោម៖ ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	
		☐ ទីកន្លែងទទួលមរណភាពនៅក្រៅប្រទេស (សូមបញ្ជាក់ឈ្មោះប្រទេស)	
☐ លំនៅឋានបច្ចុប្បន្ន ☐ លំនៅឋានបច្ចុប្បន្នរបស់ម្តាយ (មរណជនជាទារក អាយុក្រោម១ឆ្នាំ)		ផ្ទះលេខ..... ផ្លូវ..... ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	

ស្ថានភាពអាពាហ៍ពិពាហ៍	☐ នៅលីវ ☐ មេម៉ាយប្តីស្លាប់ ☐ មេម៉ាយលែងលះគ្នា ☐ កំពុងរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ	☐ បានចុះបញ្ជីអាពាហ៍ពិពាហ៍ ☐ ពោះម៉ាយប្រពន្ធស្លាប់ ☐ ពោះម៉ាយលែងលះគ្នា
កម្រិតវប្បធម៌	☐ មិនបានរៀន ☐ ថ្នាក់អនុវិទ្យាល័យ ☐ ថ្នាក់ឧត្តមសិក្សា	☐ ថ្នាក់បឋមសិក្សា ☐ ថ្នាក់វិទ្យាល័យ ☐ ផ្សេងៗ (សូមបញ្ជាក់) .....
មុខរបរ	.....	
☐ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ឬ ☐ លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ ☐ លេខលិខិតឆ្លងដែន ឬ ☐ លេខបណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជនបរទេសអន្តោប្រវេសន៍	.....	
ទីកន្លែងបូជា ឬបញ្ចុះសព	ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	
ថ្ងៃខែឆ្នាំ ម៉ោងបូជា ឬបញ្ចុះសព(២៤ម៉ោង)	ថ្ងៃទី.....ខែ.....ឆ្នាំ..... ម៉ោង.....:.....នាទី	
ព័ត៌មានឪពុកម្តាយរបស់មរណជន	**ឪពុក**	**ម្តាយ**
នាមត្រកូល	.....	.....
នាមខ្លួន	.....	.....
ជនជាតិ	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់)	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់) .....
សញ្ជាតិ	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់)	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់) .....
ថ្ងៃ ខែ ឆ្នាំកំណើត	ថ្ងៃទី ..... ខែ ..... ឆ្នាំ	ថ្ងៃទី ..... ខែ ..... ឆ្នាំ .....
ស្ថានភាព (រស់ ឬស្លាប់)	☐ រស់ ☐ ស្លាប់	☐ រស់ ☐ ស្លាប់
លំនៅឋានបច្ចុប្បន្ន	ផ្ទះលេខ ..... ផ្លូវ ..... ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	ផ្ទះលេខ ..... ផ្លូវ ..... ភូមិ ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស .....
☐ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ឬ ☐ លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ ☐ លេខលិខិតឆ្លងដែន ឬ ☐ លេខបណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជនបរទេសអន្តោប្រវេសន៍	.....	

ការចុះបញ្ជីមរណភាពក្នុងរយៈពេលអនុគ្រោះ១ឆ្នាំ ឬក្រោយផុតរយៈពេលអនុគ្រោះ១ឆ្នាំ		
☐ ករណីការចុះបញ្ជីមរណភាពក្នុងរយៈពេលអនុគ្រោះ១ឆ្នាំ បន្ទាប់ពីមរណភាពបានកើតឡើង សូមបញ្ជាក់មូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេល១៥ថ្ងៃ :		
☐ ករណីការចុះបញ្ជីមរណភាពក្រោយផុតរយៈពេលអនុគ្រោះ១ឆ្នាំ បន្ទាប់ពីមរណភាពបានកើតឡើង ១) សូមបញ្ជាក់មូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេលអនុគ្រោះ១ឆ្នាំ : ..... ២) ការធានាអះអាងសាក្សី១រូបដែលដឹងអំពីព្រឹត្តិការណ៍ សូមបំពេញព័ត៌មានសាក្សីដូចខាងក្រោម៖		
នាមត្រកូល	.....	ភេទ ☐ ប្រុស ☐ ស្រី
នាមខ្លួន	.....	
ជនជាតិ	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់)	
សញ្ជាតិ	☐ ខ្មែរ ☐ មិនអាចកំណត់បាន ☐ ផ្សេងៗ (សូមបញ្ជាក់)	
ថ្ងៃ ខែ ឆ្នាំកំណើត	ថ្ងៃទី..... ខែ..... ឆ្នាំ.....	
លំនៅឋានបច្ចុប្បន្ន	ផ្ទះលេខ..... ផ្លូវ..... ភូមិ..... ឃុំ សង្កាត់ ..... ក្រុង ស្រុក ខណ្ឌ ..... រាជធានី ខេត្ត ..... ប្រទេស	
☐ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ឬ ☐ លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ ☐ លេខលិខិតឆ្លងដែន ឬ ☐ លេខបណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត	.....	
ស្នាមមេដៃស្តាំសាក្សី	ថ្ងៃ..... ខែ..... ឆ្នាំ..... ស័ក ព.ស.២៥..... ថ្ងៃទី..... ខែ..... ឆ្នាំ២០..... ឈ្មោះ	
ព័ត៌មានអ្នករាយការណ៍		
ត្រូវជាអ្វីនឹងមរណជន : ☐ ប្តី ☐ ប្រពន្ធ ☐ ម្តាយ ☐ ឪពុក ☐ កូន ☐ ផ្សេងៗ(សូមបញ្ជាក់) ..... ប្រសិនបើអ្នករាយការណ៍មិនមែនជាម្តាយឬឪពុក សូមបំពេញព័ត៌មាន ដូចខាងក្រោម៖		
នាមត្រកូល	.....	ភេទ ☐ ប្រុស ☐ ស្រី
នាមខ្លួន	.....	
